ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយ

# ស្ដីពី

# ការថែទាំជំនួសចំពោះកុមារ

ខែមេសា ឆ្នាំ២០០៦

# មាតិកា


ទំព័រ

**ទី១ : អារម្ភកថា** ............ ១-២

**ទី២ : សារលិខិតរបស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** ............ ៣-៤

**ទី៣ : ប្រកាសស្តីពីការដាក់អោយអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ** ............ ៥-៦

**ទី៤ : គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ** ............ ៧-៣៦

I. **សេចក្តីផ្តើម** ............ ៧

II. **ឧស្សាហនានអំពីការថែទាំជំនួស** ............ ១០

III. **គំរូនៃការថែទាំជំនួសចំពោះកុមារ** ............ ១១

១. ការថែទាំក្រៅមណ្ឌល ............ ១១

ក. ការថែទាំដោយឪពុកម្តាយធម៌ ............ ១១

ខ. ការថែទាំដោយសាច់ញាតិ ............ ១២

គ. សុំកូន ............ ១២

ឃ. ការចិញ្ចឹមថែទាំនៅតាមទីវត្តអារាម និង នៅតាមទីកន្លែងជំនឿសាសនានានា ............ ១៣

ង. ក្រុមគ្រួសារ ឬ ផ្ទះដែលមានកុមារជាមេគ្រួសារ ............ ១៣

ច. ការថែទាំនៅតាមផ្ទះជាក្រុម ............ ១៤

២. ការថែទាំក្នុងមណ្ឌល ............ ១៤

ក. មណ្ឌលស្តារនីតិសម្បទា ឬ ផ្តល់កិច្ចការពារដល់កុមារ ............ ១៤

ខ. មណ្ឌលកុមារកំព្រា ............ ១៤

៣. បទដ្ឋានអប្បបរិមានៃការថែទាំជំនួសចំពោះកុមារ ............ ១៤

IV. **គោលការណ៍ស្តីពីការថែទាំជំនួស** ............ ១៥

V. **គោលនយោបាយទូទៅស្តីពីការថែទាំជំនួសចំពោះកុមារ** ............ ១៧

១. ចក្ខុវិស័យ ............ ១៧

២. បេសកកម្ម ............ ១៨

៣. ទិសដៅទូទៅ ............ ១៨

៤. ឧបសគ្គ ............ ១៩

៥. កាលានុវត្តភាព ............ ២០

៦. យុទ្ធសាស្ត្រ ............ ២១

VI. **និស្ស័យជាក់លាក់សំរាប់ការថែទាំជំនួស** ........ ២១
១. កុមារក្រោមការថែទាំរបស់ឪពុកម្តាយធម៌ ........ ២១
២. កុមារក្រោមការចិញ្ចឹមថែទាំរបស់សាច់ញាតិ ........ ២២
៣. កុមារត្រូវបានចិញ្ចឹមជាកូន ........ ២៣
៤. កុមាររស់នៅតាមទីវត្តអារាម និង នៅតាមទីកន្លែងជំនឿសាសនានានា ........ ២៤
៥. កុមាររស់នៅតាមគ្រួសារ ឬ ផ្ទះដែលមានកុមារជាមេគ្រួសារ ........ ២៥
៦. កុមាររស់នៅតាមមណ្ឌលស្តារនីតិសម្បទា មណ្ឌលកុមារកំព្រា និង កុមារទទួល បានការថែទាំនៅតាមផ្ទះជាក្រុម ........ ២៦
៧. កុមារមានទំនាស់ជាមួយច្បាប់ ........ ២៧
៨. កុមារពិការ ........ ២៨
៩. កុមារទទួលផលប៉ះពាល់ ឬ ផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍ ........ ២៩
VII. **ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល និងការប្តេជ្ញាចិត្តរបស់ មន្ត្រី និងភ្នាក់ងារផ្តល់ការថែទាំជំនួស** ........ ២៩
១. ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ........ ២៩
២. ការប្តេជ្ញាចិត្តរបស់មន្ត្រី និង ភ្នាក់ងារផ្តល់ការថែទាំជំនួស ........ ៣០
VIII. **និយមន័យ និង បញ្ហាពាក់ព័ន្ធនៅនឹងប្រភេទពិសេសនៃភាពងាយរងគ្រោះ** ........ ៣១
១. កុមារកំព្រា ........ ៣១
២. កុមារមានទំនាស់ជាមួយច្បាប់ ........ ៣១
៣. កុមាររស់នៅក្នុងគ្រួសារក្រីក្រ ........ ៣២
៤. កុមារពិការ ........ ៣២
៥. កុមារទទួលផលប៉ះពាល់ ឬ ផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍ ........ ៣២
៦. កុមារទទួលផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារ ........ ៣៣
៧. កុមារទទួលផលប៉ះពាល់ដោយសារធាតុញៀន និង អំពើអបាយមុខ ........ ៣៣
៨. កុមារអនាថាតាមចិញ្ចើមថ្នល់ ........ ៣៤
៩. កុមារត្រូវបានរំលោភបំពាន ........ ៣៤
១០. កុមារត្រូវបានកេងប្រវ័ញ្ច ........ ៣៥

**ទី៥ : ឧបសម្ព័ន្ធនៃគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ** ........ ៣៧-៣៨

# អារម្ភកថា

ប្រទេសកម្ពុជា គឺជាប្រទេសមួយស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ ដែលធ្លាប់មាន វប្បធម៌ អរិយធម៌ ដ៏រុងរឿងឧត្តុង្គឧត្តមពីអតីតកាលនាសម័យអង្គរ ។ ស្ថានភាពភូមិសាស្ត្រ ស្ថិតនៅតំបន់ដីសើមតាមដងទន្លេមេគង្គពោរពេញទៅដោយដីមានជីវជាតិអំណោយផល សំរាប់ប្រកបរបរកសិកម្ម ។

ប្រជាជនភាគច្រើនលើសលប់ជាប្រជាកសិករ ដែលមាន ចរិកស្លូតបូត ឧស្សាហ៍ព្យាយាម និង មាន ប្រពៃណី ទំនៀមទំលាប់ ចេះស្រឡាញ់រាប់អាន និង ជួយគ្នាទៅវិញទៅមក ។

ប៉ុន្តែ សង្គ្រាម និង របបប្រល័យពូជសាសន៍ ប៉ុល ពត បានធ្វើអោយប្រទេសកម្ពុជាវិនាសអន្តរាយ និង ខ្ទេចខ្ទាំយ៉ាងធ្ងន់ធ្ងរ ។ ហេដ្ឋារចនាសម្ព័ន្ធសង្គមជាតិ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ និង សីលធម៌សង្គម ដែលធ្លាប់តែល្អផូរផង់កន្លងមក ត្រូវបានស្រុតចុះដល់បាតដាល ។ របួសស្លាកស្នាមខាងផ្លូវចិត្ត ការនិរាសព្រាត់ប្រាស ប្តីសី កូនចៅ និង ញាតិសន្តាន ជាពិសេស ការបាត់បង់ សិទ្ធិ សេចក្តីថ្លៃថ្នូរ និង កិត្តិយស របស់មនុស្សត្រូវបានដក់ជាប់ក្នុងបេះដូងរបស់ប្រជាជនកម្ពុជាអស់មួយជំនាន់នៃមនុស្ស ។

ហេតុផលនេះហើយ ដែលធ្វើអោយប៉ះពាល់ ដល់ស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជាស្ទើរគ្រប់វិស័យក្នុងជំនាន់នេះ ភាពពិការខាងរូបរាងកាយ សុខភាពផ្លូវចិត្ត ភាពកំព្រាឥតទីពឹងរបស់កុមារ ភាពក្រីក្ររបស់ប្រជាជនបានបន្សល់ទុកជាមរតកសំរាប់ជាចំណោទដោះស្រាយរបស់វិស័យសង្គមកិច្ច ។

ក្រោមការដឹកនាំ ដ៏ឈ្លាសវៃរបស់ **សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា** ព្រះរាជាណាចក្រកម្ពុជាយើង បានបញ្ចប់សង្គ្រាមជាស្ថាពរ ហើយ បានកសាងប្រទេសឡើងវិញ លើបរិយាកាសសុខសន្តិភាព និងសុវត្ថិភាពនៅទូទាំងប្រទេស និង ទទួលបាននូវសមិទ្ធផលជាច្រើនលើគ្រប់វិស័យ ។

អនុវត្តតាមកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី ៣នៃរដ្ឋសភា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក៏បានរៀបចំយុទ្ធសាស្ត្រ ៦ចំណុច សំរាប់អនុវត្តលើវិស័យទាំង បី រួមមាន វិស័យសង្គមកិច្ច វិស័យអតីតយុទ្ធជន និង វិស័យយុវនីតិសម្បទា ។ និយាយដោយឡែក សុខុមាលភាពកុមារត្រូវបានយកចិត្តទុកដាក់បញ្ចូលជាយុទ្ធសាស្ត្រអាទិភាពទី ២ ក្នុងចំណោមអាទិភាពទាំង ៦ របស់ក្រសួង ។ គោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងសុខុមាលភាពកុមារត្រូវបានពិនិត្យកែលំអខ្លះៗ ឡើងវិញ ដើម្បីអោយសមស្របទៅតាមកាលៈទេសៈ ។

ការថែទាំជំនួស គឺ ជាផ្នែកមួយដ៏សំខាន់នៃសេវាកម្មចំពោះកុមារងាយរងគ្រោះ គ្រប់ប្រភេទកន្លងមក រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បានយកចិត្តទុកដាក់អនុវត្តប្រកបដោយផ្លែផ្កា និង បានផ្តល់នូវបទពិសោធន៍មួយចំនួន ។ ក្នុងសភាពការណ៍បច្ចុប្បន្ននេះ ចាំបាច់ត្រូវចងក្រងបទពិសោធន៍ទាំងអស់ ដើម្បីរៀបប្រកាសគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ សំរាប់ផ្សព្វផ្សាយអនុវត្តក្នុងក្របខណ្ឌជាតិនៃអ្នកផ្តល់សេវានេះ ចំពោះកុមារ ។

ក្រសួង បានចេញប្រកាសលេខ ៣៨ ស អ យ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការ

បង្កើតគណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ ព្រមទាំង បានបង្កើតក្រុមការងារជំនាញ ចំនួន ៤ សំរាប់ជំនួយការងារអោយគណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ ។

គោលនយោបាយស្តីពីការថែទាំចំនួសចំពោះកុមារ ជាជំហានថ្មីនៃការអនុវត្តសិទ្ធិកុមារ ទន្ទឹមនោះ កិច្ចការមួយចំនួនទៀត បាននឹងកំពុងរៀបចំជាបន្តបន្ទាប់ ដូចជា ÷

- បទដ្ឋានអប្បបរិមានៃការថែទាំជំនួសចំពោះកុមារ
- សេចក្តីព្រាងច្បាប់ស្តីកូនអន្តរប្រទេស
- គំរោងសាកល្បងគំរូនៃការថែទាំជំនួសចំពោះកុមារ
- ការចុះត្រួតពិនិត្យ និង វាយតម្លៃ ការថែទាំជំនួសចំពោះកុមារ ។ល។ និង ។ល។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខ្ញុំបាទ សូមថ្លែងអំណរគុណជ្រាលជ្រៅបំផុតចំពោះ **សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា** ដែលបានផ្តល់នូវការគាំទ្រចំពោះគោលនយោបាយនេះ តាមរយៈសារលិខិតរបស់ **សម្តេច** ចុះ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ប្តេជ្ញាអនុវត្តគោលនយោបាយនេះ អោយក្លាយទៅជាការជាក់ស្តែងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍ ដ៏ពិសិដ្ឋ សំរាប់កុមារកំព្រាគ្រប់ៗ រូប ។

ក្រសួង សូមស្វាគមន៍យ៉ាងរីករាយបំផុតចំពោះការទិទៀនិរះគន់ ក្នុងន័យស្ថាបនា ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីជួយកែលំអឯកសារគោលនយោបាយនេះ អោយកាន់តែល្អប្រសើរឡើង និង ស្របទៅតាមស្ថានភាពជាក់ស្តែងរបស់កុមារកំព្រាកម្ពុជា ។

រាជធានីភ្នំពេញ , ថ្ងៃទី ខែ ឆ្នាំ ២០០៦

**រដ្ឋមន្ត្រី**

**សម្តេច ហ៊ុន សែន**

***នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា***

# សារលិខិត

## របស់ សម្តេច ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !
- បងប្អូនជនរួមជាតិជាទីស្នេហា !

ដោយតែងតែគិតគូរ និង យកចិត្តទុកដាក់ចំពោះសិទ្ធិ និង សុខុមាលភាពកុមារ រាជរដ្ឋាភិបាលបានផ្តល់សច្ចាប័នលើ ***អនុសញ្ញាស្តីពីសិទ្ធិកុមារ*** នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយ ***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*** ឆ្នាំ១៩៩៣ បានកំណត់ច្បាស់ថា រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំ រៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬ កាមគុណលើកុមារ ។

ជាមួយគ្នានេះ រដ្ឋាភិបាល តែងតែផ្តោតការយកចិត្តទុកដាក់លើការគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និង ការរៀនសូត្ររបស់កុមារ ឬ ដែលនាំអោយអន្តរាយដល់សុខភាព ឬ សុខុមាលភាពរបស់កុមារ ។ ទន្ទឹមនឹងនោះ ដើម្បីឧត្តមប្រយោជន៍របស់កុមារកម្ពុជា បានផ្តល់សច្ចាប័នជាបន្តបន្ទាប់លើអនុសញ្ញាអន្តរជាតិមួយចំនួនទៀត ដូចជាអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ ១៣៨ ស្តីពីការកម្រិតអាយុអប្បបរិមា សម្រាប់ចូលធ្វើការងារ អនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និង សកម្មភាពបន្ទាន់ ក្នុងការលប់បំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ពិធីសាររបស់អង្គការសហប្រជាជាតិស្តីពី ការហាមប្រាមការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និង ការហាមប្រាមការធ្វើអាជីវកម្មផ្លូវភេទ និង រូបភាពអាសអាភាសកុមារ ។

ជាមួយនឹងការយកចិត្តទុកដាក់ចំពោះសិទ្ធិ និងសុខុមាលភាពកុមារ រាជរដ្ឋាភិបាលបានចាត់ទុកថាបញ្ហាកុមារ គឺជាបញ្ហាអាទិភាព ក្នុងកម្មវិធីអភិវឌ្ឍវិស័យសង្គមកិច្ចរបស់ខ្លួន ។ ក្នុងន័យនេះ គោលនយោបាយ ផែនការ និង យុទ្ធសាស្ត្រជាច្រើនរបស់ជាតិសុទ្ធតែបានដាក់បញ្ចូល និង គិតដល់បញ្ហាកុមារ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាបង្កើនអន្តរាគមន៍លើវិស័យសង្គមកិច្ច ថវិកាជាតិត្រូវបានបង្កើនជាបន្តបន្ទាប់ដល់ វិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កម្មវិធីលើកកំពស់សុខុមាលភាពកុមារ និង ជួយសង្គ្រោះជនរងគ្រោះដទៃទៀត ។ ក្នុងស្មារតីនេះ ខ្ញុំសូមអំពាវនាវឱ្យបន្តផ្តោតការយកចិត្តទុកដាក់ បង្កើនការទទួលខុសត្រូវជាចំបង ដើម្បីបំពេញកាត

ព្វកិច្ច ធានាកុមារគ្រប់រូបឱ្យបានរីកធំធាត់ ប្រកបដោយរាងកាយមាំមួន ប្រាជ្ញាឈ្លាសវៃ មានចំណេះដឹងជ្រៅជ្រះ និង ការរស់រានប្រកបដោយសេចក្ដីសុខ មានសេចក្ដីថ្លៃថ្នូរ សុភមង្គល ក្នុងក្រុមគ្រួសារ និង សង្គម ។

ក្នុងគោលបំណងទាំងអស់នេះ យើងមិនត្រឹមតែថែទាំកុមារ ដើម្បីប្រយុទ្ធប្រឆាំងនឹងជម្ងឺដង្កាត់នានា បញ្ឈប់ការធ្វើឱ្យកុមារងាយទទួលរងនូវការរងគ្រោះ និង ការធ្វើអាជីវកម្មលើកុមារ ព្រមទាំងការការពារកុមារកុំឱ្យធ្លាក់ចូលក្នុងភ្លើងនៃគ្រឿងញៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រយុទ្ធនឹងភាពក្រីក្រ តាមរយៈការវិនិយោគលើកុមារ ដោយបង្កើតនូវបរិស្ថានល្អប្រសើរសម្រាប់ការអប់រំ និង ការថែទាំសុខភាព ដើម្បីធ្វើឱ្យកុមារក្លាយខ្លួនទៅជាធនធានពិតប្រាកដ ជាទំពាំងស្នងឫស្សី ជាសរសរទ្រូងរបស់ប្រទេស និង ជាអ្នកបន្តវេនពីមនុស្សចាស់ក្នុងការអភិវឌ្ឍប្រទេសជាតិនៅក្នុងគ្រប់វិស័យ ហើយនាំសង្គមជាតិកម្ពុជាឈានឆ្ពោះទៅរកវឌ្ឍនភាពដ៏រុងរឿងនាពេលអនាគត ។

***ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ*** បានបន្តពង្រឹងសកម្មភាពជាយន្តការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធដើម្បីការពារកុមារ ។ ជាមួយគ្នានេះ បណ្ដាញការពារកុមារនៅក្នុងសហគមន៍ ត្រូវបានពង្រឹងពង្រីកតាមខេត្តជាច្រើន កម្មវិធីផ្ដល់ការគាំពារដល់កុមារដែលងាយរងគ្រោះ ដូចជា កុមារកំព្រា កុមារពិការ និង កុមារក្នុងគ្រួសារក្រីក្រក្នុងសហគមន៍ ត្រូវបានយកចិត្តទុកដាក់ ។ អំពើរំលោភបំពាន និង ការធ្វើអាជីវកម្មតាមគ្រប់រូបភាពលើកុមារ ការប្រើប្រាស់ដោយខុសច្បាប់នូវពលកម្មកុមារ អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ អំពើអនាចារ និង អសីលធម៌ផ្សេងៗទៀតលើកុមារ ត្រូវបានទប់ស្កាត់កាត់បន្ថយជាបណ្ដើរៗ ។ ទោះបីយ៉ាងនេះក៏ដោយ ក៏កុមារយើងនៅប្រឈមមុខបញ្ហាជាច្រើនទៀត ដូចជា ភាពក្រីក្រ ផលប៉ះពាល់ដោយជម្ងឺអេដស៍ ការសេពគ្រឿងញៀន អំពើអនាចារ ការប៉ះពាល់ខាងផ្លូវច្បាប់ ជាដើម ។

ក្នុងនាមរាជរដ្ឋាភិបាល និង ក្នុងឋានៈជាប្រធានកិត្តិយសនៃ ***ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ*** ខ្ញុំសូមគាំទ្រទាំងស្រុងចំពោះគោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ និង សូមសម្ដែងការកោតសរសើរចំពោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលបានផ្ដួចផ្ដើមសហការជាមួយ អង្គការ ***យូនីសេហ្វ (UNICEF)*** និង ស្ថាប័នពាក់ព័ន្ធដទៃទៀត រៀបចំគោលនយោបាយដ៏មានសារៈសំខាន់នេះ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឆ្លងតាមការអនុវត្តនូវគោលនយោបាយនេះ សិទ្ធិទាំងបួន និង សុខុមាលភាពរបស់កុមារ នឹងត្រូវបានលើកស្ទួយ និង គោរពយ៉ាងខ្ជាប់ខ្ជួន ។ ខ្ញុំសូមឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បន្តកសាងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀត ពិសេសបទដ្ឋានអប្បបរិមានៃការថែទាំជំនួសចំពោះកុមារ ដើម្បីរួមចំណែកបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តគោលនយោបាយនេះ ។ ខ្ញុំសូមអំពាវនាវដល់ក្រសួង ស្ថាប័នវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ដែលពាក់ព័ន្ធ និង សង្គមស៊ីវិលនានា ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមផ្ដល់ការឧបត្ថម្ភគាំទ្រ ព្រមទាំងបន្តសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្នុងការផ្សព្វផ្សាយ និង អនុវត្តគោលនយោបាយនេះ ឱ្យទៅជាការជាក់ស្ដែង ដើម្បីបុព្វហេតុកុមារកម្ពុជា តាមពាក្យស្លោក ***"យើងទាំងអស់គ្នាគាំទ្រ និង ជំរុញការអនុវត្តសិទ្ធិកុមារ"*** ។

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

អគ្គនាយកដ្ឋានបច្ចេកទេស

លេខៈ ២១៧ សអយ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦

# ប្រកាស

# ស្តីពី

# ការដាក់អោយអនុវត្តគោលនយោបាយ

# ស្តីពីការថែទាំជំនួសចំពោះកុមារ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្ម នុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ . បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញប្រកាស លេខ ០៣៨ ស អ យ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពី ការបង្កើតគណៈកម្មាធិការប្រឹក្សាការថែទាំចំលាស់ ចំពោះកុមារ

# សម្រេច

**ប្រការ១ :** ត្រូវបានដាក់អោយអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ។ គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ លេខ ៩០៧ ស អ យ ចុះ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០០៦ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២ :** បទប្បញ្ញត្តិដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣ :** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានសុខុមាលភាពកុមារ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត - ក្រុង អង្គការជាតិ អង្គការអន្តរជាតិ និង ដៃគូពាក់ព័ន្ធទាំងអស់ មានភារកិច្ចអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

**<u>ចំលងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សៅ្យ ឆាញ់**
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
" ដើម្បីគោរពជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ
" ដើម្បីជូនជ្រាប និង សហការអនុវត្ត "
- ដូចប្រការ ៣ " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

អគ្គនាយកដ្ឋានបច្ចេកទេស

លេខៈ ៩០៧ សអយ

*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦*

# គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

## I. សេចក្តីផ្តើម

កុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះមួយ ឬ ច្រើនប្រភេទ ដូចមានរៀបរាប់ខាងក្រោមនេះ ត្រូវបានចាត់ទុកថាជាប្រភេទកុមារត្រូវការកិច្ចការពារពិសេស ឬ កុមារប្រឈមមុខនឹងគ្រោះថ្នាក់ ។ កុមារត្រូវការកិច្ចការពារពិសេស រួមមាន ÷

- កុមារកំព្រា
- កុមារដែលត្រូវបានបោះបង់ចោល
- កុមារដែលទទួលផលប៉ះពាល់ ឬ ផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍
- កុមារដែលទទួលរងការរំលោភបំពានផ្លូវភេទ រូបរាងកាយ ឬ ផ្លូវចិត្ត
- កុមារអនាថាតាមចិញ្ចើមថ្នល់
- កុមារមានទំនាស់ជាមួយច្បាប់
- កុមារដែលរងគ្រោះដោយសារអំពើកេងប្រវ័ញ្ចផ្លូវភេទ ឬទំរង់ពលកម្មប្រកបដោយគ្រោះថ្នាក់
- កុមារពិការ
- កុមារញៀនសារធាតុញៀន
- កុមារដែលមិនបានទទួលនូវតំរូវការផ្នែករូបវន្តជាមូលដ្ឋាន ។

ប្រភេទកុមារដែលប្រឈមមុខនឹងគ្រោះថ្នាក់មានទំនាក់ទំនងទៅនឹងបរិបទមួយចំនួនដូចជា ÷ភាពក្រីក្រខ្លាំង ការបែកបាក់គ្រួសារ ការសេពគ្រឿងស្រវឹង ការលេងល្បែងស៊ីសង អំពើហិង្សាក្នុងគ្រួសារ ការបោះបង់ចោលការសិក្សា ការរស់នៅក្នុងតំបន់តាំងទីលំនៅថ្មី (ជនចំណាកស្រុក ជនបំលាស់ទីលំនៅ ជនមាតុភូមិនិវត្តន៍ គ្រួសារយោធារំសាយ ) ជីវិតរស់នៅជាមួយអ្នកដែលពុំមែនជាឪពុកម្តាយបង្កើត ។ ពលរដ្ឋកម្ពុជាជាង ៣០% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ហើយ ៥២% មានអាយុក្រោម១៨ ឆ្នាំ ភាពក្រីក្រកំពុងតែមានឥទ្ធិពលយ៉ាងខ្លាំងក្លា និង ជាក់ស្តែងទៅលើកុមារ និង ពលរដ្ឋវ័យក្មេង ។

កន្លងមក ពាក្យថា " កុមារកំព្រា " ត្រូវបានប្រើសំរាប់ពិពណ៌នា កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ ហើយដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ បានទទួលមរណៈភាព ។ នៅចុងឆ្នាំ ២០០៣ មាន កុមារកំព្រាចំនួន ៦៧០.០០០ នាក់ នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ នៅក្នុងនោះគេពុំបានដឹងថា កុមារប៉ុន្មាន នាក់ កំព្រាឪពុក កំព្រាម្តាយ ឬ កំព្រាទាំងឪពុកទាំងម្តាយនោះឡើយ ។

វត្តមានរបស់កុមារអនាថាតាមចិញ្ចើមថ្នល់នៅតាមទីក្រុងធំៗ គឺជាផលវិបាកនៃបញ្ហាសង្គមមក លើកុមារ ដែលកុមារចាំបាច់ត្រូវទទួលបានការការពារ និង ថែទាំ ។ កុមារអនាថាតាមចិញ្ចើមថ្នល់ ចាប់ ផ្តើមមានឡើងកាលពីដើមទសវត្សរ៍ ទី៩០ ប៉ុន្តែ ចំនួនកុមារទាំងនោះ ហាក់ដូចជា នៅថេរ នៅក្នុងប៉ុន្មាន ឆ្នាំចុងក្រោយនេះ។ កុមារទាំងនោះ ផ្តាច់ការទាក់ទងទាំងស្រុងជាមួយក្រុមគ្រួសារ ឬគ្មានគ្រួសារ ហើយ យកចិញ្ចើមថ្នល់ធ្វើជាផ្ទះសម្បែង ។ កុមារអនាថាតាមចិញ្ចើមថ្នល់ ក៏រាប់បញ្ចូលផងដែរ នូវកុមារដែល ចំណាយពេលច្រើនបំផុតដើររកស៊ី និង រស់នៅតាមចិញ្ចើមថ្នល់ ប៉ុន្តែ នៅរក្សាទំនាក់ទំនងជាមួយ ក្រុម គ្រួសារនៅឡើយ ។ នៅក្នុងទីក្រុងភ្នំពេញ មានកុមារអនាថា ចំនួន ៥៤៦ នាក់ តាមការស្រាវជ្រាវរបស់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រាជធានីភ្នំពេញ ក្នុងឆ្នាំ ២០០៤ ។ ចំនួននេះមាន ការប្រែប្រួលមិនទៀងទាត់ទៅតាមស្ថានភាពនៅតាមខេត្ត ។

ដោយការបែងចែកប្រភេទកុមារអនាថាអាចមានភាពជាន់គ្នា ហើយ កត្តាងាយរងគ្រោះមានការ ពាក់ព័ន្ធគ្នាទៅវិញទៅមក កុមារអនាថាតាមចិញ្ចើមថ្នល់ ពុំមែនគ្រាន់តែ ខ្វះលទ្ធភាពទៅសាលារៀន ឬ ទទួលបានការថែទាំសុខភាពប៉ុណ្ណោះទេ ប៉ុន្តែ កុមារទាំងនោះច្រើនតែត្រូវគេធ្វើបាប និងកេងប្រវ័ញ្ចថែម ទៀតផង ជាពិសេស ដោយមេក្រុមបងធំ ដែលទាញយកផលប្រយោជន៍ពីកុមារទាំងនោះ ព្រមទាំងបាន បង្ខិតបង្ខំអោយកុមារលួចគេទៀតផង ។ កុមារទាំងនោះ ជាច្រើននាំគ្នាហិតការ ហើយ ជាញឹកញាប់ពួក គេច្រើនតែរងគ្រោះ ដោយសារការរំលោភ ឬ កេងប្រវ័ញ្ចផ្លូវភេទ ដែលនាំអោយពួកគេងាយរងគ្រោះ ដោយការឆ្លងមេរោគអេដស៍ ។ កុមារទាំងនោះ ក៏ អាចធ្លាក់ខ្លួនទៅនៅតាមចិញ្ចើមថ្នល់ ដោយសារ នៅ ក្នុងក្រុមគ្រួសារមានអ្នកផ្ទុកមេរោគ ឬ កើតជម្ងឺអេដស៍ ។ ការឆ្លងរាលដាលមេរោគអេដស៍ ត្រូវបានគេ ចាត់ទុកថា គឺ ជាកត្តាចំបងដែលនាំអោយកុមារធ្លាក់ខ្លួនទៅក្នុងស្ថានភាពត្រូវការការថែទាំនៅក្រៅរង្វង់ គ្រួសារ ឬក៏បណ្តាលអោយកុមារធ្លាក់ខ្លួនកំព្រា ។ ជាការពិត ពលរដ្ឋដែលមានអត្រាផ្ទុកមេរោគ និង កើត ជម្ងឺអេដស៍ខ្ពស់បំផុត គឺជាក្រុមមនុស្ស ដែលស្ថិតក្នុងវ័យត្រូវចិញ្ចឹមថែទាំកុមារ ។ យោងតាមមជ្ឈមណ្ឌល ជាតិប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ សើស្បែក និង កាមរោគ បានអោយដឹងថា កាលពី ឆ្នាំ ២០០៣ មានមនុស្ស ចំនួន ១២៣.១០០នាក់ ដែលមានអាយុចាប់ពី ១៥ ទៅ ៤៩ ឆ្នាំ កំពុងផ្ទុកមេរោគ និង កើត ជម្ងឺអេដស៍ ដែលជាអត្រាប្រេវ៉ាឡង់ ១.៩ ភាគរយ សំរាប់មនុស្សក្នុងក្រុមអាយុនេះ ។

លើសនេះទៅទៀត ការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ និង ការជួញដូរ គឺជាបញ្ហាមួយដែលបាន និង កំពុងរីករាលដាលនៅទូទាំងប្រទេស ចាប់តាំងពីដើមទសវត្សរ៍ ឆ្នាំ១៩៩០ មក ។ ទោះបីជា ពុំមានតួលេខថ្នាក់ជាតិក៏ដោយ ក៏ការអង្កេត ទ្រង់ទ្រាយតូចជាច្រើន បានបង្ហាញថា នៅឆ្នាំ ២០០៣ មានអ្នករកស៊ីផ្លូវភេទចំនួន ១៨.២៥៦ នាក់ ដែលក្នុងនោះ មានប្រហែលជា ២.០០០ នាក់ ត្រូវបានគេជួញដូរដោយបង្ខំ ហើយជាអនីតិជនផងដែរ ។ ភាគច្រើននៃអ្នកទាំងនេះ ត្រូវបានមនុស្សដែលស្គាល់គ្នា លួងលោមអោយធ្លាក់ខ្លួនក្នុងមុខរបរនេះ ។ ពួកគេធ្វើផ្ទុយនឹងឆន្ទៈរបស់ខ្លួនគេកាន់តែខ្លាំង បើគេមានអាយុកាន់តែតិច ។ ការជួញដូរឆ្លងដែនកំពុងតែជាបញ្ហាគួរចាប់អារម្មណ៍ ។ មានកុមារីជនជាតិបរទេសខ្លះត្រូវបានគេជួញដូរចូលមកក្នុងប្រទេសកម្ពុជា ដើម្បីរកស៊ីផ្លូវភេទ និង ធ្វើពលកម្មតាមរូបភាពផ្សេងទៀត នៃការកេងប្រវ័ញ្ច ហើយក៏មានកុមារ និងស្ត្រីកម្ពុជា ត្រូវបានគេជួញដូរទៅប្រទេសជិតខាង អោយសុំទាន អោយធ្វើការបំរើសេវាជួញដូរផ្លូវភេទ ។

សព្វថ្ងៃនេះ តាមរបាយការណ៍នានាបានអោយដឹងថា ករណីកុមារមានទំនាស់ជាមួយច្បាប់ កំពុងតែមានចំនួនកើនឡើង ជាពិសេសនៅក្នុងទីក្រុងភ្នំពេញ ក្នុងនោះរួមមាន កុមារអនាថាតាមចិញ្ចើមថ្នល់ដែលពាក់ព័ន្ធនឹងសកម្មភាពល្មើសច្បាប់ ព្រមទាំងយុវជននៃក្រុមបងធំ ។ ទោះជា មានលិខិតបទដ្ឋានមួយចំនួនដែលពាក់ព័ន្ធនឹងអនីតិជនក៏ដោយ តែចាំបាច់ត្រូវជំរុញអោយមាន ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និង តុលាការកុមារ ។

កន្លងមកអនីតិជនខ្លះ ដែលបានប្រព្រឹត្តបទល្មើស ត្រូវបានគេបញ្ជូនទៅកាន់ មជ្ឈមណ្ឌលយុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ហើយខ្លះទៀតត្រូវដាក់នៅក្នុងពន្ធនាគារជាមួយមនុស្សពេញវ័យ ។

កុមារប្រឈមមុខនឹងគ្រោះថ្នាក់ និង កុមារដែលត្រូវការកិច្ចការពារពិសេសអាចមានពេលខ្លះត្រូវការការថែទាំជំនួស ។ ចំនួនកុមារដែលកំពុងទទួលការថែទាំជំនួស បានបង្ហាញអោយឃើញ អំពីវិសាលភាពនៃបញ្ហានេះ ។ គេបានប៉ាន់ស្មានឃើញថា មានកុមារចំនួន២០.៣៤៨នាក់ កំពុងរស់នៅក្រោមការថែទាំជំនួស គិតមកដល់ ខែ វិច្ឆិកា ឆ្នាំ២០០១ ដែលក្នុងនោះ មានកុមារចំនួន ១១.៤៧០ នាក់បានទទួលការថែទាំនៅតាមមណ្ឌល ។

ឯកសារគោលនយោបាយនេះ នឹងណែនាំជាដំបូងអោយយល់ដឹងទស្សនាទានខ្លះៗ អំពីការថែទាំជំនួស ( ជំពូកII ) មុននឹងអោយនិយមន័យអំពីសេវាថែទាំតាមរូបភាពផ្សេងៗ តាមការយល់ឃើញរបស់អ្នកចូលរួមចំណែកបំរើការងារវិស័យនេះ នៅក្នុងប្រទេសកម្ពុជា ( ជំពូកIII ) ។ គោលការណ៍ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយ ចែងអំពីអន្តរាគមន៍ នៃការថែទាំជំនួស នៅក្នុងប្រទេសកម្ពុជា មាន

បង្ហាញជូននៅក្នុង ជំពូក IV ហើយបន្តមកទៀត មានការបង្ហាញជូនខ្លឹមសារសំខាន់ៗ នៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ( ជំពូក V ) ។ ជំពូកបន្ទាប់នៅក្នុងឯកសារនេះ (ជំពូក VI ) ថែងអំពីទិសដៅជាក់លាក់ពាក់ព័ន្ធទៅ និង ប្រភេទផ្សេងៗ នៃការថែទាំជំនួស និង ភាពងាយរងគ្រោះ ។ មានជំពូកមួយទៀត (ជំពូក VII )ថែងអំពីភារកិច្ចទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល និង ការប្តេជ្ញាចិត្តរបស់អ្នកផ្តល់ការថែទាំជំនួស ។ ជំពូកចុងក្រោយ (ជំពូក VIII ) ថែងអំពីនិយមន័យ និង បញ្ហាដែលទាក់ទងទៅនឹងប្រភេទជាក់លាក់នីមួយៗ នៃភាពងាយរងគ្រោះ ។

## II. ទស្សនាទានអំពីការថែទាំជំនួស

ដូចបានលើកឡើងនៅក្នុងសេចក្តីផ្តើមរួចមកហើយ គឺមានកុមារផ្សេងៗមួយចំនួន ក្នុងនោះមានទាំងកុមារខ្លះ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយរបស់ខ្លួននៅឡើយផងដែរ ដែលពេលខ្លះអាចត្រូវការនូវការថែទាំជំនួសក្នុងមួយដំណើរជីវិតរស់នៅរបស់ខ្លួន ។ គោលនយោបាយនេះ ផ្តោតតែទៅលើការថែទាំជំនួស ដែលជាការថែទាំសំរាប់កុមារកំព្រា និង កុមារដែលងាយរងគ្រោះឯទៀតៗ ដែលពុំមែនជាកុមារស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើត ។ការថែទាំជំនួសមានពីរប្រភេទដូចតទៅនេះ ÷ ការថែទាំក្នុងស្ថាប័ន ឬ ការថែទាំក្នុងមណ្ឌលស្នាក់នៅ និង ការថែទាំក្រៅមណ្ឌល ឬ ការថែទាំនៅតាមសហគមន៍ ឬ តាមគ្រួសារ ។

- ***ការថែទាំក្នុងស្ថាប័ន ឬ ក្នុងមណ្ឌលស្នាក់នៅ*** គឺ ការចាត់ចែងរៀបចំអោយកុមាររស់នៅជុំគ្នាជាក្រុម ក្រោមការថែទាំរបស់បុគ្គលិកមណ្ឌល ដែលទទួលប្រាក់បៀវត្សរ៍សំរាប់ផ្តល់សេវាថែទាំ ឧទាហរណ៍ ដូចជា មណ្ឌលកុមារកំព្រា មណ្ឌលស្តារនីតិសម្បទា មណ្ឌលផ្តល់កិច្ចការពារដល់កុមារជាដើម ។ កុមារដែលរស់នៅក្នុងមណ្ឌលខាងលើនេះ បានទទួលការថែទាំពេញលេញក្នុងមួយរយៈពេលសមស្រប ។ ជាក់ស្តែង ការថែទាំនៅតាមមណ្ឌលបែបនេះ ត្រូវបានបង្កើតឡើង និង ដំណើរការដោយរដ្ឋ ឬ ដោយអង្គការក្រៅរដ្ឋាភិបាលនានា ។ ជាទូទៅ មណ្ឌលទាំងនេះច្រើនតែ ដោះស្រាយសេចក្តីត្រូវការជាក់ស្តែងរបស់កុមារ ដោយផ្តល់ការថែទាំរយៈពេលខ្លី និង រយៈពេលវែងតាមហេតុផលសមស្រប ។ ទោះជាយ៉ាងនេះ ក៏ដោយ ក៏ការសិក្សាស្រាវជ្រាវជាច្រើន បានបង្ហាញអោយឃើញថា ការដាក់កុមារអោយនៅក្រោមការថែទាំរបស់មណ្ឌល រយៈពេលយូរ អាចមានការប៉ះពាល់ដល់ការអភិវឌ្ឍន៍របស់កុមារ ដូចជា អាចបណ្តាលអោយមានការប្រកាន់រើសអើង ការកេងប្រវ័ញ្ចលើកុមារ ។ ល ។ ដូច្នេះ ត្រូវជំរុញលើកកំពស់អោយមានការថែទាំក្រៅមណ្ឌល ។

- ***ការថែទាំក្រៅមណ្ឌល*** គឺជាការថែទាំនៅតាមក្រុមគ្រួសារ និង នៅតាមសហគមន៍ ។ ជាទូទៅ ការថែទាំប្រភេទនេះ អាចអនុវត្តន៍តាមរូបភាពជាច្រើន ដូចជា ការចិញ្ចឹមកុមារជាកូនចិញ្ចឹម ការថែទាំដោយឪពុកម្តាយធម៌ ការថែទាំដោយសាច់ញាតិ និង ការថែទាំនៅតាមទីវត្តអារាម ។ ការថែទាំជំនួសតាមរូបភាពមួយផ្សេងទៀត ដែលកើតមានថ្មីៗនេះ ដោយសារការរីករាលដាលនៃមេរោគ និង ជម្ងឺអេដស៍ នោះគឺការថែទាំនៅតាមក្រុមគ្រួសារ ឬ តាមផ្ទះដែលមានកុមារជាមេគ្រួសារ ។

ការថែទាំក្រៅមណ្ឌល ដែលមានសេវាថែទាំមិនពេញពេលផ្តល់ដោយមនុស្សពេញវ័យ ហើយមិនមានពាក់ព័ន្ធជាសាច់ញាតិជាមួយកុមារ ដូចជា នៅតាមមណ្ឌលសំចតបណ្តោះអាសន្ន មណ្ឌលថែទាំពេលថ្ងៃ និង សកម្មភាពផ្សេងៗទៀត ចុះដល់មូលដ្ឋាន ជាដើម មិនបានរាប់បញ្ចូលនៅក្នុងគោលនយោបាយនេះទេ ។

## III. គំរូនៃការថែទាំជំនួសចំពោះកុមារ

គំរូនៃការថែទាំជំនួសចំពោះកុមារ រួមមាន សេវាពីរប្រភេទ គឺ : ការថែទាំក្រៅមណ្ឌល និង ការថែទាំក្នុងមណ្ឌល ។

### ១. ការថែទាំក្រៅមណ្ឌល

#### ក. ការថែទាំដោយឪពុកម្តាយធម៌

ការថែទាំដោយឪពុកម្តាយធម៌ គឺជាទំរង់មួយនៃការប្រគល់កុមារទៅអោយគ្រួសារមួយដែលពុំមែនជាសាច់ញាតិរបស់កុមារ ហើយដែលបានយល់ព្រមទទួលចិញ្ចឹមថែទាំកុមារជាបណ្តោះអាសន្ន ។ ជាទូទៅ ការចិញ្ចឹមថែទាំបែបនេះ ច្រើនតែមានរយៈពេលខ្លី ហើយពុំមានពាក់ព័ន្ធទៅនឹងការផ្ទេរសិទ្ធិ និងភារកិច្ចទទួលខុសត្រូវជាអចិន្ត្រៃយ៍របស់ឪពុកម្តាយទេ (សូមមើលត្រង់ចំណុចសុំកូន ) ។ គោលបំណងសំខាន់នៃការចិញ្ចឹមថែទាំបែបនេះ គឺ នៅទីបំផុតត្រូវបង្រួបបង្រួមកុមារអោយបានទៅរស់នៅជួបជុំ ជាមួយក្រុមគ្រួសារបង្កើតវិញ ឬ រស់នៅក្នុងគ្រួសារណាមួយ ដែលទទួលយកកុមារជាកូនចិញ្ចឹមរហូតជាអចិន្ត្រៃយ៍ ។ ការអនុវត្តន៍បែបនេះ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ហើយជាទូទៅពុំមានពាក់ព័ន្ធជាមួយកិច្ចព្រមព្រៀងផ្លូវច្បាប់ឡើយ ។ ប៉ុន្តែ ការយកកុមារទៅចិញ្ចឹមជាកូនធម៌បែបនេះ អាចផ្អែកលើកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ ដែលធ្វើឡើងរវាង ឪពុកម្តាយបង្កើត ឪពុកម្តាយធម៌ អាជ្ញាធរមូលដ្ឋាន ឬ អាជ្ញាធរថ្នាក់កណ្តាល និងអង្គការណាមួយ ។

## ខ. ការថែទាំដោយសាច់ញាតិ

ការថែទាំដោយសាច់ញាតិ គឺជាស្ថានភាពមួយ ដែលសមាជិកក្នុងក្រុមគ្រួសារធំមួយ ទទួលយកកុមារកំព្រា ឬ កុមារដទៃៗទៀត មកចិញ្ចឹមនៅក្នុងគ្រួសាររបស់ខ្លួន ។ អ្នកថែទាំចិញ្ចឹមកុមារទាំងនោះ អាចជាជីដូនជីតា ម្តាយធំ ម្តាយមីង ឪពុកធំ ឪពុកមា ឬជាសាច់ញាតិដទៃទៀតរបស់កុមារនោះ។ ការទទួលកុមារយកទៅចិញ្ចឹមបែបនេះមានច្រើន ហើយក៏ចាក់ឫសយ៉ាងជ្រៅផងដែរនៅក្នុងប្រទេសកម្ពុជា ។ ការយកកុមារទៅចិញ្ចឹមថែទាំបែបនេះអាចផ្អែកលើកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរដែលធ្វើឡើងរវាងឪពុកម្តាយបង្កើត សាច់ញាតិ ដែលយកកុមារទៅចិញ្ចឹម អាជ្ញាធរមូលដ្ឋាន ឬ អាជ្ញាធរថ្នាក់កណ្តាល ហើយនិង អង្គការណាមួយ ។

## គ. សុំកូន

សុំកូន គឺជាប្រភេទមួយនៃការដាក់កុមារអោយរស់នៅក្នុងគ្រួសារមួយជាអចិន្ត្រៃយ៍ ដោយអោយឪពុកម្តាយបង្កើតរបស់កុមារផ្ទេរសិទ្ធិ និង ភារកិច្ចទទួលខុសត្រូវទាំងអស់ជូនទៅឪពុកម្តាយចិញ្ចឹម ហើយកុមារដែលគេយកទៅចិញ្ចឹមនោះ ត្រូវទទួលបានឋានៈ សិទ្ធិ និង កាតព្វកិច្ចនានាដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះដែរ ។ ការចិញ្ចឹមកុមារបែបនេះ អាចធ្វើអោយមានការផ្តាច់ទំនាក់ទំនងទាំងស្រុង ជាមួយគ្រួសារបង្កើតរបស់កុមារ បើសិនជា ការចិញ្ចឹមនោះមានលក្ខណៈជាសុំកូនពេញលេញ ។ សុំកូនពេញលេញ បង្កើតអោយមានទំនាក់ទំនងជាអចិន្ត្រៃយ៍រវាងកូនសុំជាមួយនឹង ឪពុកម្តាយចិញ្ចឹម ហើយ បញ្ចប់ជាស្ថាពរសិទ្ធិ និង កាតព្វកិច្ច រវាងកូនជាមួយឪពុកម្តាយបង្កើត ឬ ជាមួយអ្នកអាណាព្យាបាល ។ ការសុំកុមារយកទៅចិញ្ចឹម អាចជាការចិញ្ចឹមនៅក្នុងប្រទេស ឬ យកទៅក្រៅប្រទេស ។ តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ បានចែងថាការសុំកូនយកទៅចិញ្ចឹមត្រូវធ្វើឡើងដោយមានកិច្ចសន្យាជាលាយលក្ខណ៍អក្សររវាងឪពុកម្តាយចិញ្ចឹម និង កុមារដែលត្រូវគេសុំយកទៅចិញ្ចឹម ( តាមរយៈឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលរបស់កុមារ ) ដែលត្រូវបញ្ជាក់ដោយ ក្រុមប្រឹក្សាឃុំ -សង្កាត់ ដែល ឪពុកម្តាយចិញ្ចឹម ឬ ដែលកុមាររស់នៅ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ការសុំកូនយកទៅចិញ្ចឹមបែបនេះអាចត្រូវចាត់ទុកជាមោឃៈវិញបានដែរ ដោយតុលាការ បើសិនជា មានពាក្យបណ្តឹងពីកុមារ ឬ ពីជនណាម្នាក់ ឬ ពីអង្គការណាមួយ ដែលតវ៉ាពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់កុមារ ។

ការសុំកូនយកទៅចិញ្ចឹមក្នុងប្រទេស ទោះជា ការចិញ្ចឹមនោះមានលក្ខណៈធម្មតា ឬ ពេញលេញក៏ដោយ ក៏ឪពុកម្តាយចិញ្ចឹម និង ឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលរបស់កុមារ ត្រូវតែធ្វើ និង ដាក់ពាក្យបណ្តឹងតាមរយៈតុលាការដែរ ។ ក្នុងករណីការចិញ្ចឹមជាលក្ខណៈធម្មតា តុលាការ

អាចរំលាយចោលការសុំកូនទៅចិញ្ចឹមបែបនេះវិញបាន បើភាគីទាំងឡាយព្រមព្រៀងគ្នា ។ ក្នុងករណីចិញ្ចឹមពេញលេញ តុលាការក៏អាចរំលាយចោលការសុំកូនទៅចិញ្ចឹមបែបនេះវិញបានដែរ បើរកឃើញថាមានអំពើឃោរឃៅកើតឡើង មានការបោះបង់កុមារចោល ឬ អ្នកចិញ្ចឹមបានប្រព្រឹត្ត ឬ ធ្វើអោយបាត់បង់នូវឧត្តមប្រយោជន៍របស់កុមារ ( មានចែងក្នុងសេចក្តីព្រាងច្បាប់រដ្ឋប្បវេណី[ខ] ) ។

ជនម្នាក់ ឬ ប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍ ដែលជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសក្រៅមួយ

អាចសុំកុមារយកទៅចិញ្ចឹមបាន បើកុមារដែលគេចង់សុំយកទៅចិញ្ចឹមនោះ ជាកុមាររស់នៅក្នុងមណ្ឌលកុមារកំព្រាមួយ ឬ រស់នៅក្នុងមណ្ឌលថែទាំយូរអង្វែងមួយ ដែលគ្រប់គ្រង ឬ ទទួលខុសត្រូវ ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬ ដោយអង្គការក្រៅរដ្ឋាភិបាលណាមួយ ដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចបានទទួលស្គាល់ ។ ពាក្យសុំកូនយកទៅចិញ្ចឹម ត្រូវតែដាក់ជូន និង យល់ព្រមដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច មុនពេលពាក្យបណ្តឹងសុំកូនយកទៅចិញ្ចឹម ត្រូវតុលាការកម្ពុជាបើកសវនាការ និង ចេញសាលក្រមទទួលស្គាល់ (មានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីសុំកូនអន្តរប្រទេស[ខ] ) ។

### ឃ. ការចិញ្ចឹមថែទាំនៅតាមទីវត្តអារាម និង នៅតាមទីកន្លែងជំនឿសាសនានានា

នៅក្នុងសង្គមកម្ពុជាដែលប្រជាជនភាគច្រើនគោរពព្រះពុទ្ធសាសនា វត្តអារាមមានតួនាទីសំខាន់ក្នុងការផ្តល់ការថែទាំជំនួស ដល់កុមារ ។ ព្រះសង្ឃ ដូនជី និង លោកអាចារ្យ ជាអ្នកផ្តល់ដល់កុមារនូវចំណីអាហារ ជំរក ការអប់រំ ជាដើម ។ ឆ្លងតាមពិសោធន៍នេះ គប្បីពិចារណារិះរកវិធីស្រដៀងគ្នានេះដែរ ដើម្បីផ្តល់ការចិញ្ចឹមថែទាំកុមារក្នុងមជ្ឈដ្ឋានប្រជាជនដែលមានដើមកំណើត ជំនឿ និង គោរពសាសនាផ្សេងៗទៀត ។

### ង. ក្រុមគ្រួសារ ឬ ផ្ទះដែលមានកុមារជាមេគ្រួសារ

ក្រុមគ្រួសារ ឬ ផ្ទះ ដែលមានកុមារជាមេគ្រួសារ គឺជាក្រុមកុមារកំព្រា ដែលជាបងប្អូននឹងគ្នារស់នៅក្រោមការទទួលខុសត្រូវ និង ការចិញ្ចឹមថែទាំរបស់កុមារ ដែលមានវ័យច្រើនជាងដោយសារឪពុកម្តាយ ឬ សាច់ញាតិ បានស្លាប់ចោល ឬ ក៏ ពិការអសមត្ថភាព ។ ដោយសារ ការឆ្លងរីករាលដាលនៃមេរោគ និង ជំងឺអេដស៍ ជាមូលហេតុមួយ ធ្វើអោយគ្រួសារប្រភេទនេះ មានការកើន

ឡើង ដៃគូផ្តល់ជំនួយមួយចំនួនបានផ្តល់អនុសាសន៍ថា ត្រូវមានវិធានការចាំបាច់ ដើម្បីកាត់បន្ថយការកើនឡើងនៃគ្រួសារ ឬផ្ទះដែលមានកុមារជាមេគ្រួសារ និងដើម្បីបង្កើតយន្តការសំរាប់គាំទ្រដល់ក្រុមគ្រួសារ ឬ ផ្ទះដែលមានកុមារជាមេគ្រួសារ ដែលមានស្រាប់ហើយ ។

**ច. ការថែទាំនៅតាមផ្ទះជាក្រុម**

ការថែទាំនៅតាមផ្ទះជាក្រុម គឺជារូបភាពនៃការថែទាំជំនួសមួយបែប ដែលគេដាក់អោយកុមារមួយចំនួនមានកំណត់រស់នៅក្នុងផ្ទះមួយជាមួយគ្នា ជាបរិយាកាសគ្រួសារមួយក្រោមអភិបាលកិច្ចរបស់អ្នកផ្តល់សេវាថែទាំមួយក្រុមតូច ដែលពុំមែនជាសាច់ញាតិរបស់កុមារ ។ ផ្ទះជាក្រុមនេះត្រូវបានគេរៀបចំអោយស្ថិតនៅក្នុងសហគមន៍មួយ ប៉ុន្តែ ពុំមែននៅក្រោមការចាត់ចែងគ្រប់គ្រងរបស់សហគមន៍ទេ ។

## ២. ការថែទាំក្នុងមណ្ឌល

**ក. មណ្ឌលស្តារនីតិសម្បទា ឬ ផ្តល់កិច្ចការពារដល់កុមារ**

មណ្ឌលស្តារនីតិសម្បទា ផ្តល់ចំណីអាហារដល់កុមារ ដែលត្រូវបានរំលោភបំពាន ដែលត្រូវបានកេងប្រវ័ញ្ច និងដែលរងគ្រោះដោយការប្រើប្រាស់សារធាតុញៀន កុមាររស់នៅតាមចិញ្ចើមថ្នល់ ឬ កុមាររស់នៅក្នុងស្ថានភាពលំបាកណាមួយផ្សេងៗ ទៀត ។ បន្ថែមពីលើសេចក្តីត្រូវការចាំបាច់សំរាប់ការអភិវឌ្ឍន៍ មណ្ឌលទាំងនេះមានផ្តល់សេវាពិសេសៗ ដូចជា ការផ្តល់ប្រឹក្សាដែលមានពាក់ព័ន្ធទៅនឹងស្ថានភាពនានា ដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់កុមារ ការអប់រំ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ខ. មណ្ឌលកុមារកំព្រា**

មណ្ឌលកុមារកំព្រា ជាទូទៅ គឺជាមណ្ឌលសំរាប់ការស្នាក់នៅយូរអង្វែងដែលផ្តល់អ្វី ។ ទៅតាមតំរូវការចាំបាច់សំរាប់ការអភិវឌ្ឍន៍របស់កុមារ ដែលបានបាត់បង់ ឪពុក ឬ ម្តាយ ឬ បាត់បង់ទាំងឪពុកទាំងម្តាយបង្កើត ។ ជាការពិត មណ្ឌលទាំងនេះ ក៏ទទួលយកផងដែរនូវកុមារ ដែលប្រឈមមុខនឹងគ្រោះថ្នាក់ ឬ ត្រូវការកិច្ចការពារពិសេស ប៉ុន្តែ មណ្ឌលទាំងនេះពុំអាចផ្តល់សេវាពិសេសបានទេ ។

## ៣. បទដ្ឋានអប្បបរិមានៃការថែទាំជំនួសចំពោះកុមារ

ដោយយោលទៅតាមការអនុវត្តន៍ជាក់ស្តែង ហើយនិង ស្ថានភាពសំខាន់ៗបែបនេះ រាជរដ្ឋា

ភិបាល និង ដៃគូអ្នកផ្តល់ជំនួយនៅក្នុងប្រទេសកម្ពុជាជាច្រើន បានឯកភាព បង្កើតបទដ្ឋានអប្ប បរិមានៃការថែទាំជំនួស ដូចខាងក្រោម ÷

- ***ការថែទាំនៅតាមសហគមន៍ និង ក្រុមគ្រួសារ*** គឺ ជាយុទ្ធវិធីមួយ ក្នុងចំណោមយុទ្ធវិធីជាច្រើន ដែលត្រូវបានរៀបចំ និង គ្រោងឡើង សំរាប់ជួយកុមារអោយបន្តរស់នៅក្នុងក្រុមគ្រួសារសាច់ញាតិរបស់ខ្លួន ឬ យកកុមារទៅដាក់អោយគ្រួសារណាមួយចិញ្ចឹម នៅក្នុងសហគមន៍របស់ខ្លួនបើអាចធ្វើបាន ។ ក្រុមគ្រួសារ ដែលយើងបានរៀបរាប់នៅក្នុងបរិបទ នេះ រួមមាន គ្រួសារធំ ដែលផ្តល់ការថែទាំរបៀបជា សាច់ញាតិ គ្រួសារដែលមានកុមារជា មេគ្រួសារ និង គ្រួសារធម៌ ដែលមិនមែនជា សាច់ញាតិរបស់កុមារ ។
- ***ការថែទាំនៅតាមទីវត្តអារាម និង នៅតាមទីកន្លែងជំនឿសាសនានានា :*** នៅក្នុងសង្គមកម្ពុជាដែលប្រជាជនភាគច្រើនគោរពព្រះពុទ្ធសាសនា វត្តអារាមមានតួនាទីសំខាន់ក្នុងការផ្តល់ការថែទាំជំនួស ដល់កុមារ ។ ព្រះសង្ឃ ដូនជី និង លោកអាចារ្យ ជាអ្នកផ្តល់ដល់កុមារនូវ ចំណីអាហារ ជំរក ការអប់រំ ជាដើម ។ ឆ្លងតាមពិសោធន៍នេះ គប្បីពិចារណារិះរកវិធីស្រដៀងគ្នានេះដែរ ដើម្បីផ្តល់ការចិញ្ចឹមថែទាំកុមារក្នុងមជ្ឈដ្ឋានប្រជាជន ដែលមាន ដើមកំណើត ជំនឿ និង គោរពសាសនាផ្សេងៗទៀត ។
- ***ការថែទាំនៅតាមផ្ទះជាក្រុម*** គឺជាទំរង់រូបភាពមួយនៃការថែទាំជំនួស ដែលកុមារមានចំនួនកំណត់ ត្រូវបានដាក់អោយរស់នៅក្នុងផ្ទះមួយរួមគ្នាជាលក្ខណៈគ្រួសារក្រោមអភិបាលកិច្ចរបស់អ្នកផ្តល់ការថែទាំមួយក្រុមតូច ដែលពុំមែនជាសាច់ញាតិរបស់កុមារ ។ ការរស់នៅក្នុងផ្ទះជាក្រុមបែបនេះ មានលក្ខណៈជាការរស់នៅក្នុងសហគមន៍មួយ ប៉ុន្តែ ពុំមែនគ្រប់គ្រងដោយសហគមន៍ទេ ។
- ***ការថែទាំនៅក្នុងមណ្ឌល*** រួមមាន មណ្ឌលកុមារកំព្រា និង មណ្ឌលស្តារនីតិសម្បទា ។ ការរៀបចំអោយរស់នៅរយៈពេលខ្លី ឬរយៈពេលវែងបែបនេះ មានមនុស្សពេញវ័យដែលបានទទួលបៀវត្សរ៍ជាអ្នកផ្តល់សេវាថែទាំដល់កុមារទាំងនេះពេញម៉ោង ។

## IV. គោលការណ៍ស្តីពីការថែទាំជំនួស

រាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ឧបត្ថម្ភរាល់សេចក្តីត្រូវការរបស់កុមារ ដែលងាយរងគ្រោះបំផុតតាមរយៈការផ្តល់សេវាសមស្រប និង កិច្ចការពារមិនអោយមានគ្រោះថ្នាក់ ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ[ii] នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ។ អនុលោមតាមអនុសញ្ញានេះ រាជរដ្ឋាភិបាល បានបង្កើតគោលនយោបាយ ដើម្បីធានាអោយកុមារដែលពុំមានផ្ទះ ពុំមានគ្រួសារ ត្រូវទទួលបានការថែទាំជំនួស ។ អនុលោមទៅតាមសេចក្តីប្រកាសលើកទី២នៃសន្និសីទក្រុងស្តុក

ខុលស្តីពីកុមារ និង ការថែទាំនៅតាមមណ្ឌល[រ៉ិ] នាខែ ឧសភា ឆ្នាំ ២០០៣ និង សេចក្តីប្រកាសនៃសន្និសីទ ដែលបានប្រារព្ធធ្វើឡើងកាលពីខែ តុលា ឆ្នាំ ២០០៣ ក្រោយសេចក្តីប្រកាសទីក្រុងស្តុកខុលនេះ នៅក្នុងទីក្រុងភ្នំពេញ ដែលរៀបចំដោយ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា[ខ] រាជរដ្ឋាភិបាលកម្ពុជាបានសំរេចដាក់ចេញបណ្តាគោលការណ៍ទាំងឡាយដូចខាងក្រោមនេះ÷

- ការថែទាំតាមគ្រួសារ និង តាមសហគមន៍ គឺជាជំរើសដ៏ល្អបំផុត សំរាប់ការថែទាំជំនួស
- ការថែទាំក្នុងមណ្ឌលគួរតែជាជំរើសចុងក្រោយ និង ជាដំណោះស្រាយបណ្តោះអាសន្ន
- ត្រូវបង្កើតយុទ្ធសាស្ត្រ និង វិធានការជាក់លាក់ ដើម្បីគាំទ្រមាតាបិតា សំរាប់ចិញ្ចឹមកូនចៅរបស់ខ្លួន និង បញ្ជូនកូនចៅទាំងនោះអោយទៅរៀន
- យុទ្ធសាស្ត្រ និង វិធានការទាំងនេះ ក៏ ត្រូវផ្តោតផងដែរ ទៅលើ ក្រុមគ្រួសារ សាច់ញាតិ សហគមន៍ ដែលផ្តល់ការថែទាំដល់កុមារ ដែលគ្មានឪពុកម្តាយថែទាំ ដើម្បីចៀសវាងការបញ្ជូនកុមារទៅទទួលសេវានៅតាមមណ្ឌល
- ក្នុងករណីមិនអាចអោយកុមារចៀសផុតពីការចូលទៅរស់នៅក្នុងមណ្ឌលបាន ត្រូវអនុវត្តបទដ្ឋានអប្បបរិមា និង គោលការណ៍ណែនាំសំរាប់ផ្តល់ការថែទាំតាមមណ្ឌល ហើយត្រូវតាមដានពិនិត្យ និង វាយតំលៃ ស្របទៅតាមបណ្តាគោលការណ៍ទាំងបួន នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ :
  - គោលការណ៍ស្តីពី ***ឧត្តមប្រយោជន៍*** របស់កុមារ
  - គោលការណ៍ស្តីពី ***ការមិនប្រកាន់រើសអើង***
  - គោលការណ៍ស្តីពី ***សិទ្ធិរស់រានមានជីវិត អភិវឌ្ឍ និង ទទួលបានកិច្ចការពារ***
  - គោលការណ៍ស្តីពី ***ការចូលរួម*** របស់កុមារ ក្នុងការអភិវឌ្ឍន៍របស់ខ្លួន

- ការថែទាំនៅក្នុងមណ្ឌល ឬ ការថែទាំនៅតាមសហគមន៍ ឬ នៅតាមក្រុមគ្រួសារ ត្រូវអនុវត្តអោយបានក្នុងកំរិតអប្បបរិមានៃបទដ្ឋានដែលមានចែងនៅក្នុងក្របខ័ណ្ឌ គោលនយោបាយនេះ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាស្ថាប័នមានសមត្ថកិច្ចទទួលខុសត្រូវ ក្នុងការដឹកនាំ និង អនុវត្តគោលនយោបាយនេះ ។ ការផ្តល់សេវាថែទាំជំនួសរបស់អង្គការក្រៅរដ្ឋាភិបាល ត្រូវមានការអនុញ្ញាត និង មានចុះកិច្ចព្រមព្រៀង ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។

ត្រូវគោរពថានានុក្រម នៃជំរើសដោយប្រកាន់ខ្ជាប់ នូវការការពារឧត្តមប្រយោជន៍រយៈពេលវែងរបស់កុមារ នៅពេលធ្វើការសំរេចចិត្តយកវិធានការណាមួយក្នុងការថែទាំកុមារ :

- ***ដំណោះស្រាយតាមគ្រួសារ*** ដូចជា វិលត្រឡប់ ឬ បញ្ជូនត្រឡប់ អោយទៅរស់នៅជាមួយ គ្រួសារបង្កើត គ្រួសារធម៌ គ្រួសារចិញ្ចឹមធ្វើជាកូន ល្អប្រសើរជាងបញ្ជូនទៅកាន់មណ្ឌល ។
- ***ដំណោះស្រាយអចិន្ត្រៃយ៍*** ដូចជា វិលត្រឡប់ ឬ បញ្ជូនត្រឡប់ អោយទៅរស់នៅជាមួយ គ្រួសារបង្កើត គ្រួសារចិញ្ចឹមធ្វើជាកូន ល្អប្រសើរជាងបញ្ជូនទៅរកដំណោះស្រាយបណ្តោះអាសន្ន ។
- ***ដំណោះស្រាយថ្នាក់ជាតិ*** ដូចជា វិលត្រឡប់ ឬ បញ្ជូនត្រឡប់ អោយទៅរស់នៅជាមួយ គ្រួសារបង្កើត គ្រួសារចិញ្ចឹមធ្វើជាកូននៅក្នុងសហគមន៍ គ្រួសារចិញ្ចឹមធ្វើជាកូនក្នុងប្រទេស ល្អប្រសើរជាងបញ្ជូនទៅរកដំណោះស្រាយជាអន្តរជាតិ ។

នៅពេលអនុវត្តបណ្តាគោលការណ៍ និង បណ្តាថានានុក្រមខាងលើ ចាំបាច់ត្រូវគិតបញ្ចូលនូវវិស័យដ៏ទៃទៀត នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ÷

- ការបន្តផ្តល់ការអប់រំ ចិញ្ចឹម ថែរក្សា និង រក្សាពូជសាសន៍កំណើត វប្បធម៌ និង ភាសា
- ការលើកទឹកចិត្ត អោយរក្សាទំនាក់ទំនងរវាងកុមារ ដែលទទួលការថែទាំជំនួស និង ក្រុមគ្រួសាររបស់កុមារតាមលទ្ធភាពដែលអាចធ្វើបាន ព្រមទាំង ត្រូវមានកំណត់ត្រា និង រក្សាឯកសារបានត្រឹមត្រូវ និង ទាន់ពេលជានិច្ច
- កុមារត្រូវមានសិទ្ធិពិនិត្យឡើងវិញ នូវប្រព្រឹត្តិកម្មចំពោះខ្លួន និង ស្ថានភាពដ៏ទៃទៀត ដែលកុមាររស់នៅ
- កុមារមិនត្រូវបានដកហូតសិទ្ធិ និង សេរីភាពឡើយ
- ការជ្រើសរើសដោយសំរិតសំរាំងនូវបុគ្គលិក ដែលជាអ្នកផ្តល់ការថែទាំជំនួស ដែលត្រូវជាមនុស្សធ្លាប់បានទទួលបានការបណ្តុះបណ្តាល និង បានទទួលប្រាក់ឧបត្ថម្ភសមរម្យ
- កុមារម្នាក់ៗ មានសិទ្ធិ និងមានលក្ខណៈដោយឡែករៀងៗខ្លួនដែលយើងត្រូវគិតគូរពិចារណា នៅពេលធ្វើការសំរេចចិត្តទៅលើអ្វីមួយដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់កុមារ
- កុមារដែលជាបងប្អូនបង្កើត មិនត្រូវអោយរស់នៅដាច់ឡែកពីគ្នា ឬ បែកពីគ្នា ឡើយ លើកលែងតែករណីក្នុងកាលៈទេសៈខ្លះប៉ុណ្ណោះដែលចៀសវាងពុំបាន ។

## V. គោលនយោបាយទូទៅស្តីពីការថែទាំជំនួសចំពោះកុមារ

### ១. ចក្ខុវិស័យ

កុមារទាំងអស់មានលទ្ធភាព និង មានសិទ្ធិទទួលបានការថែទាំ ដែលអនុវត្ត និង គោរពសិទ្ធិរបស់កុមារសំរាប់ការរស់រាន ការទទួលបានកិច្ចការពារ ការអភិវឌ្ឍន៍ និង ការចូលរួម ។ តួនាទីបឋម

ក្នុងការការពារ និង ការថែទាំកុមារត្រូវបំពេញដោយក្រុមគ្រួសាររបស់កុមារផ្ទាល់ ។

## ២. បេសកកម្ម

អនុវត្តតាមកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង បណ្តាក្រសួង ស្ថាប័នផ្សេងៗ ទៀត បានប្តេជ្ញាអនុវត្ត គោលនយោបាយ និង កម្មវិធីស្តីពីការថែទាំជំនួសនេះ ប្តេជ្ញាកសាងសមត្ថភាពបុគ្គលិក ដែលអនុវត្តការងារជាមួយកុមារ និង ដើម្បីកុមារ ព្រមទាំងបង្កើតប្រព័ន្ធពិនិត្យ តាមដាន និង វាយតំលៃ ដែលធានាការអនុវត្តន៍ប្រកបទៅដោយប្រសិទ្ធិភាពនិងមានទំនាក់ទំនងសមស្របរវាងសហគមន៍ និង កុមារដែលពុំមានអ្នកថែទាំបឋម ។

អនុវត្តទៅតាមបណ្តាអនុសាសន៍ នៃការសង្កេតចុងក្រោយ របស់គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលបានផ្សព្វផ្សាយនៅក្នុងសម័យប្រជុំលើកទី ៦៤១ កាលពី ខែឧសភា ឆ្នាំ ២០០០ ព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាដូចខាងក្រោមនេះ ÷

- ចាត់វិធានការប្រកបដោយប្រសិទ្ធិភាព សំរាប់លើកស្ទួយក្រុមគ្រួសារ ដែលជាបរិយាកាសប្រសើរបំផុតសំរាប់កុមារ និង ផ្តល់សិទ្ធិអំណាចជូនមាតាបិតាសំរាប់ថែទាំកូនរបស់ខ្លួន ដើម្បីចៀសវាងពីការយកកុមារទៅទទួលការថែទាំនៅក្នុងមណ្ឌលតាមរយៈកម្មវិធីផ្តល់ប្រឹក្សា និង កម្មវិធី ដែលមានមូលដ្ឋាននៅតាមសហគមន៍
- បង្កើតគោលនយោបាយ និង បទបញ្ញានានាពាក់ព័ន្ធទៅនឹងការថែទាំក្នុងមណ្ឌល និង ការថែទាំជំនួសក្នុងទំរង់រូបភាពផ្សេងៗទៀត ។ ត្រូវមានការចាប់អារម្មណ៍ពិសេស ចំពោះកុមារដែលធ្លាក់ខ្លួនកំព្រា ដោយសារការរីករាលដាលនៃមេរោគ និង ជម្ងឺអេដស៍ ដើម្បីបង្កើនលទ្ធភាពរបស់កុមារអោយអាចទទួលបានការថែទាំក្រៅមណ្ឌល ដូចជា ទៅរស់នៅទទួលការថែទាំក្នុងគ្រួសារធម៌ ជាដើម ។
- បន្តការងារធ្វើច្បាប់ស្តីពីសុំកូនអន្តរប្រទេស និង ច្បាប់ស្តីពីសុំកូនក្នុងប្រទេស ។

## ៣. ទិសដៅទូទៅ

ទិសដៅទូទៅនៃគោលនយោបាយនេះ គឺការពារសិទ្ធិរបស់កុមារ និង ធានាការអភិវឌ្ឍន៍ផ្លូវកាយ ផ្លូវចិត្ត បញ្ញាស្មារតី យូរអង្វែងរបស់កុមារកំព្រា និង កុមារងាយរងគ្រោះផ្សេងទៀត ។ គោលនយោបាយនេះ មានគោលបំណង ÷

- ធានាអោយកុមារបានទទួលផលប្រយោជន៍ ពីលិខិតូបករណ៍ច្បាប់ជាតិ និង អន្តរជាតិ ជា

ពិសេស ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និង គោលការណ៍ទាំងបួនរបស់អនុសញ្ញា

- ធានាអោយកុមារបានរីកចំរើនល្អតលាស់នៅក្នុងក្រុមគ្រួសារ និងនៅក្នុងសហគមន៍ ពិសេសក្នុងគ្រួសារបង្កើត និង សហគមន៍ ជាកន្លែងដើម ឬ ស្រុកកំណើត
- ធានាអោយកុមារមានលទ្ធភាពទទួលបានសេវាសុខភាព សេវាអប់រំ ដោយឥតគិតថ្លៃ និងការគាំទ្រផ្លូវចិត្ត ដើម្បីអោយកុមារអាចរស់រាន និង អភិវឌ្ឍ
- បង្កើនសមត្ថភាពសហគមន៍សំរាប់ថែទាំ និង ការពារកុមារងាយរងគ្រោះ តាមរយៈការលើកស្ទួយ និង ពង្រឹងបណ្តាញសុវត្ថិភាពទាំងអស់របស់សហគមន៍ ។

## ៤. ឧបសគ្គ

ការអនុវត្តន៍កម្មវិធីទូលំទូលាយ និង ពេញលេញ ដើម្បីជួយដល់កុមារងាយរងគ្រោះនឹងជួបបញ្ហាប្រឈមទូទៅមួយចំនួន ÷

- ការយល់ដឹងអំពីសិទ្ធិកុមារនៅមានកំរិត
- ការយល់ដឹងអំពីបញ្ហាសង្គមនៅគ្រប់ជាន់ថ្នាក់នៅមានកំរិត
- កង្វះធនធានសំរាប់អនុវត្តកម្មវិធីគ្រប់វិស័យទាំងអស់
- ការពិបាកក្នុងការផ្តល់អាទិភាពទៅលើបញ្ហានានាពាក់ព័ន្ធទៅនឹង គោលដៅ និង ទិសដៅដែលអាចសំរេចបាន
- ក្របខ័ណ្ឌច្បាប់ដែលមិនទាន់បង្កើតបានគ្រប់គ្រាន់
- ការអនុវត្តន៍ច្បាប់ជាតិ និង លិខិតូបករណ៍ច្បាប់អន្តរជាតិ ដែលកម្ពុជាបានផ្តល់សច្ចាបន័មិនបានគ្រប់គ្រាន់
- ការសំរបសំរួលនៅមានកំរិតក្នុងចំណោមស្ថាប័នរដ្ឋ ក៏ដូចជា ជាមួយអង្គការនានា និង សង្គមស៊ីវិល ដែលធ្វើការពាក់ព័ន្ធទៅនឹងកុមារងាយរងគ្រោះ
- កង្វះប្រព័ន្ធរួមនៃ ការពិនិត្យ និង តាមដាននៅគ្រប់ថ្នាក់ និង កង្វះលទ្ធភាពទទួលបាននូវពត៌មាន
- ផលវិបាកមួយចំនួនដែលបណ្តាលមកពីទំនើបភាវូបនីយកម្ម ដូចជា បុគ្គលនិយម ការចុះថយនៃតំលៃទំនៀមទំលាប់ប្រពៃណី ការថយចុះនៃសាមគ្គីភាព ជាដើម ។

កុមារងាយរងគ្រោះ និង អ្នកផ្តល់ការថែទាំជំនួសនឹងជួបបញ្ហាប្រឈមជាក់ស្តែង ដូចខាងក្រោមនេះ ÷

- កង្វះការគាំទ្រ និង កង្វះបរិយាកាសជាគ្រួសារ
- ការប្រឈមមុខនឹងការធ្វើបាបផ្លូវភេទ និង ការកេងប្រវ័ញ្ចផ្លូវភេទ

- កង្វះវិធីសាស្ត្រអប់រំអំពីសេចក្តីស្នេហា ឬ ការរួមភេទ ដែលសមស្របតាមវ័យរបស់កុមារនិងតាមប្រពៃណីជាតិ
- កង្វះលទ្ធភាពទទួលបាន សេវាអប់រំ សេវាសុខភាព និង សេវាស្តារនីតិសម្បទា
- កង្វះ និង ពុំមានការយល់ដឹងគ្រប់គ្រាន់អំពីទំរង់ថ្មីៗ នៃការថែទាំជំនួស
- ការលំបាក ក្នុងការទទួលបានមរតក និង កេរ្តិ៍ដំណែល
- ការប្រកាន់រើសអើង និង ការមិនយកចិត្តទុកដាក់ចំពោះកុមារ ដែលប្រឈមនឹងកត្តាងាយរងគ្រោះ
- កុមារងាយរងគ្រោះមានចំនួនកើនឡើង ដោយសារ មេរោគ និង ជំងឺអេដស៍
- បន្ទុកនៃការទទួលខុសត្រូវដំបូង និង ការបាត់បង់ឱកាសទទួលការអប់រំ ឱកាសលេងកំសាន្ត និង ការសិរបសិរួលខ្លួនក្នុងសង្គម ជាពិសេសសំរាប់កុមារដែលរស់នៅក្នុងក្រុមគ្រួសារ ដែលមានកុមារជាមេគ្រួសារ និង ទទួលការថែទាំនៅតាមមណ្ឌល
- ដែនអនុវត្តនៃកម្មវិធីថែទាំជំនួស នៅមិនទាន់បានទូលំទូលាយ
- កុមារ ក្រុមគ្រួសារ សហគមន៍ បុគ្គលិកជំនាញខ្វះចំណេះដឹងផ្នែកការគាំទ្រ និងសេវាបញ្ជូនដែលកំពុងអនុវត្តបច្ចុប្បន្ន
- កុមារខ្វះ ខ្វះសេចក្តីទុកចិត្តទៅលើរចនាសម្ព័ន្ធផ្លូវការ
- រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា នៅមានកំរិតនៅឡើយ គឺមាននៅត្រឹម ថ្នាក់ស្រុក ខណ្ឌ
- ក្រុមប្រឹក្សាឃុំសង្កាត់ ខ្វះបទពិសោធន៍ក្នុងការងារសង្គមកិច្ច ដោយសារក្រុមប្រឹក្សានេះ ទើបតែដំណើរការបានមួយអាណត្តិប៉ុណ្ណោះ ។

## ៥. កាលានុវត្តភាព

កាលានុវត្តភាពមួយចំនួនដូចខាងក្រោម អាចមានសក្តានុពលក្នុងការរួមវិភាគទានធ្វើអោយល្អប្រសើរឡើងដល់ការជួយឧបត្ថម្ភចំពោះកុមារងាយរងគ្រោះ ÷

- ឆន្ទៈខាងនយោបាយចំពោះកិច្ចការពារកុមារ និង ការលើកស្ទួយសិទ្ធិរបស់កុមារមាននៅគ្រប់ថ្នាក់
- ការធ្វើវិមជ្ឈការមុខងាររបស់រាជរដ្ឋាភិបាល បានជួយគាំទ្រ ដល់ការបង្កើតរចនាសម្ព័ន្ធ ដែលមានការចូលរួមនៅតាមសហគមន៍ ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ បានទទួលអាណត្តិការងារសង្គមកិច្ច និង បានទទួលឱកាសកសាងសមត្ថភាព

- គោលដៅអភិវឌ្ឍសហស្សវត្សរ៍ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល បានឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់គ្រួសារក្រីក្រ ដើម្បីទទួលបាន ការគាំទ្រល្អប្រសើរ
- រាជរដ្ឋាភិបាល បានផ្តល់សច្ចាប័នលើអនុសញ្ញា និងពិធីសារជាច្រើនដែលទាក់ទងទៅនឹងសិទ្ធិ របស់កុមារ[ii]
- រាជរដ្ឋាភិបាល មានការប្តេជ្ញាចិត្តអនុវត្តដំណោះស្រាយតាមគ្រួសារ ដំណោះស្រាយ អចិន្ត្រៃយ៍ និង ដំណោះស្រាយថ្នាក់ជាតិ ។

### ៦. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តទិសដៅជាក់លាក់ និង យុទ្ធសាស្ត្រទាក់ទងទៅនឹងទំរង់ពិសេស១ នៃការថែទាំជំនួស នោះ ចាំបាច់ត្រូវមានយុទ្ធសាស្ត្រទូទៅ ដើម្បីដោះស្រាយនូវសេចក្តីត្រូវការរបស់កុមារកំព្រា និង កុមារងាយរងគ្រោះ តាមរយៈលក្ខណៈចំរុះវិស័យ ÷

- ធ្វើការប៉ាន់ប្រមាណជាទៀងទាត់អំពីសេចក្តីត្រូវការតាមវិស័យនានា ដែលប៉ះពាល់ដល់កុមារ កំព្រា និង កុមារងាយរងគ្រោះដទៃទៀត
- បង្កើតក្របខ័ណ្ឌគោលនយោបាយ ដែលផ្តោតលើសិទ្ធិកុមារសំរាប់គ្រប់គ្រង និងធ្វើអោយទៅ ជាផ្លូវការនូវកម្មវិធី និងសេវា ដែលលើកស្ទួយសុខុមាលភាពរបស់កុមារកំព្រា និងកុមារងាយ រងគ្រោះដទៃ១ទៀត
- បង្កើនលទ្ធភាពអោយកុមារកំព្រា និង កុមារងាយរងគ្រោះដទៃ១ទៀត ទទួលបានសេវាមូល ដ្ឋានចាំបាច់
- ធ្វើការពិនិត្យតាមដាន និងវាយតំលៃយ៉ាងទៀងទាត់ ដើម្បីធានាអោយកម្មវិធីទាំងឡាយដែល តំរង់ទិសទៅរកកុមារកំព្រា និងកុមារងាយរងគ្រោះផ្សេង១ទៀត បំពេញបានរាល់សេចក្តីត្រូវ ការរបស់កុមារ និង ដើម្បីធានាអោយការអភិវឌ្ឍន៍កម្មវិធីចេះតែបន្តមានជារៀងរហូតទៅ ។

## VI. ទិសដៅជាក់លាក់សំរាប់ការថែទាំជំនួស

### ១. កុមារក្រោមការថែទាំរបស់ឪពុកម្តាយធម៌

ក. បង្កើតក្របខ័ណ្ឌគោលនយោបាយ សំរាប់គ្រប់គ្រង និងធ្វើអោយទៅជាផ្លូវការនូវការថែទាំដោយ ឪពុកម្តាយធម៌ រួមមាន លទ្ធភាពទទួលបានតួនាទី និង ការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និង គោលការណ៍ណែនាំ ។ ត្រូវមានចែងខ្លឹមសារដោយឡែក ដើម្បីធានាអោយកុមារដែល

ទទួលការថែទាំដោយឪពុកម្តាយធម៌ អាចមានលទ្ធភាពទទួលបានមរតក ។

ខ. នៅក្នុងក្របខ័ណ្ឌគោលនយោបាយនេះ លើកស្ទួយការថែទាំដោយឪពុកម្តាយធម៌អោយអនុវត្តទៅតាមកម្មវិធីរបស់រដ្ឋ កម្មវិធីអង្គការក្រៅរដ្ឋាភិបាល និង នៅតាមក្រុមគ្រួសារ រួមមាន តាមរយៈការផ្តល់ការគាំទ្រផ្ទាល់ចំពោះការថែទាំ និង ការអប់រំ កុមារ ។

គ. រៀបចំអោយទៅជាផ្លូវការ បង្កើត និង ពិនិត្យ តាមដានបទដ្ឋាននានា ផ្អែកលើក្របខ័ណ្ឌគោលនយោបាយ ។

ឃ. បង្កើតយន្តការអភិបាលកិច្ច និងផ្តល់កិច្ចការពារនៅតាមសហគមន៍សំរាប់កុមារដែលទទួលការថែទាំ ដោយឪពុកម្តាយធម៌ ដោយប្រកាន់យករចនាសម្ព័ន្ធ និង ការទទួលខុសត្រូវ ជាលក្ខណៈវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។

ង. កសាងសមត្ថភាព មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង មន្ត្រីក្រសួងពាក់ព័ន្ធឯទៀតៗ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ក្រុង និង ថ្នាក់ស្រុក ខណ្ឌ មន្ត្រីដែលជាអ្នកផ្តល់សេវាថែទាំជំនួស ដោយផ្តោតលើការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយនេះ ។

ច. មុនពេលយកកុមារទៅដាក់នៅក្រោមការថែទាំដោយឪពុកម្តាយធម៌ មន្ត្រីដែលបំរើការងារនេះត្រូវស្តាប់កុមារ រួចប្រាប់កុមារអោយដឹងពីទីកន្លែងដែលកុមារត្រូវទៅរស់នៅ (សិទ្ធិ និងការទទួលខុសត្រូវរបស់គ្រួសារក៏ដូចជារបស់កុមារ) ហើយក្រុមគ្រួសារត្រូវមានលក្ខណៈសមស្របទៅតាមលក្ខណៈវិនិច្ឆ័យ ដែលក្របខ័ណ្ឌគោលនយោបាយនេះ បានកំណត់ ។

ឆ. ពិនិត្យឡើងវិញនូវករណីមុនៗ ដែលកុមារបានរស់នៅ និង ទទួលបានការថែទាំដោយ ឪពុកម្តាយធម៌ ដោយផ្ទៀងផ្ទាត់ ប្រៀបធៀប ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយនេះ ។

## ២. កុមារក្រោមការចិញ្ចឹមថែទាំរបស់សាច់ញាតិ

ក. បង្កើតក្របខ័ណ្ឌគោលនយោបាយសំរាប់គ្រប់គ្រង និង ធ្វើអោយទៅជាផ្លូវការនូវការចិញ្ចឹមថែទាំរបស់សាច់ញាតិ រួមមាន លទ្ធភាពទទួលបានតួនាទី ការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និង គោលការណ៍ណែនាំ ។ ត្រូវមានចែងខ្លឹមសារដោយឡែក ដើម្បីធានាអោយកុមារក្រោមការចិញ្ចឹមថែទាំរបស់សាច់ញាតិ អាចមានលទ្ធភាពទទួលបានមរតក ។

ខ. នៅក្នុងក្របខ័ណ្ឌគោលនយោបាយនេះ លើកស្ទួយការចិញ្ចឹមថែទាំរបស់សាច់ញាតិ អោយអនុវត្តទៅតាមកម្មវិធីរបស់រដ្ឋ កម្មវិធីអង្គការក្រៅរដ្ឋាភិបាល និង នៅតាមក្រុមគ្រួសារ រួមមាន តាមរយៈការផ្តល់ការគាំទ្រផ្ទាល់ចំពោះការថែទាំ និង ការអប់រំកុមារ ។

គ. រៀបចំអោយទៅជាផ្លូវការ បង្កើត និង ពិនិត្យ តាមដានបទដ្ឋាននានា ផ្អែកលើក្របខ័ណ្ឌគោលនយោបាយ ។

ឃ. បង្កើតយន្តការអភិបាលកិច្ច និង ផ្តល់កិច្ចការពារនៅតាមសហគមន៍សំរាប់កុមារក្រោមការចិញ្ចឹមថែទាំរបស់សាច់ញាតិ ដោយប្រកាន់យករចនាសម្ព័ន្ធ និង ការទទួលខុសត្រូវជាលក្ខណៈវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។

ង. កសាងសមត្ថភាពមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង មន្ត្រីក្រសួងពាក់ព័ន្ធឯទៀត។ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ក្រុង និង ថ្នាក់ស្រុក ខណ្ឌ មន្ត្រីដែលជាអ្នកផ្តល់សេវាថែទាំជំនួសដោយផ្តោតលើការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយនេះ ។

ច. មុនពេលយកកុមារទៅដាក់នៅក្រោមសេវាចិញ្ចឹមថែទាំរបស់សាច់ញាតិ មន្ត្រីដែលបំរើការងារនេះ ត្រូវស្តាប់កុមាររួចប្រាប់កុមារអោយដឹងពីទីកន្លែងដែលកុមារត្រូវទៅរស់នៅ (សិទ្ធិ និង ការទទួលខុសត្រូវរបស់គ្រួសារក៏ដូចជារបស់កុមារ) ហើយ ក្រុមគ្រួសារ ត្រូវមានលក្ខណៈសមស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលក្របខ័ណ្ឌគោលនយោបាយនេះ បានកំណត់ ។

ឆ. ពិនិត្យឡើងវិញនូវករណីមុន។ ដែលកុមារបានរស់នៅ និងទទួលការចិញ្ចឹមថែទាំដោយសាច់ញាតិដោយផ្ទៀងផ្ទាត់ ប្រៀបធៀប ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយនេះ ។

### ៣. កុមារត្រូវបានចិញ្ចឹមជាកូន

ក. បង្កើតក្របខ័ណ្ឌគោលនយោបាយ សំរាប់គ្រប់គ្រង និង ធ្វើអោយទៅជាផ្លូវការ នូវការសុំកុមារយកទៅចិញ្ចឹមក្នុងប្រទេស និង ក្រៅប្រទេស រួមមាន លទ្ធភាពទទួលបានតួនាទី ការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និង គោលការណ៍ណែនាំ ។ ត្រូវមានចែងខ្លឹមសារដោយឡែក ដើម្បីធានាអោយកុមារដែលត្រូវបានយកទៅចិញ្ចឹមមានលទ្ធភាព និង មានសិទ្ធិទទួលមរតក ។

ខ. នៅក្នុងក្របខ័ណ្ឌគោលនយោបាយនេះ លើកស្ទួយការចិញ្ចឹមកុមារជាកូននៅតាមក្រុមគ្រួសារ ទៅតាមកម្មវិធីរបស់រដ្ឋ និង កម្មវិធីអង្គការក្រៅរដ្ឋាភិបាល រួមមាន តាមរយៈការផ្តល់ការគាំទ្រផ្ទាល់ចំពោះការថែទាំ និង ការអប់រំកុមារ ។

គ. រៀបចំអោយទៅជាផ្លូវការ បង្កើត និង ពិនិត្យ តាមដានបទដ្ឋាននានា ផ្អែកលើក្របខ័ណ្ឌគោលនយោបាយ ។

ឃ. កសាងសមត្ថភាព មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង មន្ត្រីក្រសួងពាក់ព័ន្ធឯទៀត។ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ក្រុង និង ថ្នាក់ស្រុក ខណ្ឌ មន្ត្រីដែលជាអ្នកផ្តល់សេវាថែទាំជំនួសដោយផ្តោតលើការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយនេះ ។ បុគ្គលិកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវដឹងពីតួនាទីរបស់ខ្លួនទាក់ទិនទៅនឹងយន្តការអភិបាលកិច្ច និង កិច្ចការពារកុមារ ដែលត្រូវបានសុំយកទៅចិញ្ចឹម ។

ង. ការពារសិទ្ធិកុមារដើម្បីអោយមានអត្តសញ្ញាណដោយខិតខំប្រឹងប្រែងអោយអស់ពីលទ្ធភាពដើម្បី

បញ្ជូនកុមារទៅកាន់គ្រួសារបង្កើតមុនពេលអោយយកកុមារទៅចិញ្ចឹមជាកូន ។

ច. មុនពេលប្រគល់កុមារអោយយកទៅចិញ្ចឹម ត្រូវស្តាប់កុមាររួចប្រាប់កុមារអោយដឹងពីទីកន្លែង ដែលកុមារត្រូវទៅរស់នៅ ( សិទ្ធិ និង ការទទួលខុសត្រូវរបស់គ្រួសារ ក៏ដូចជា របស់កុមារ ) ហើយក្រុមគ្រួសារដែលនឹងយកកុមារទៅចិញ្ចឹមនោះត្រូវមានលក្ខណៈសមស្របទៅតាមលក្ខណៈវិនិច្ឆ័យ ដែលក្របខ័ណ្ឌគោលនយោបាយនេះ បានកំណត់ ។

ឆ. ពិនិត្យឡើងវិញនូវករណីមុនៗ ដែលកុមារត្រូវបានចិញ្ចឹមជាកូន ដោយផ្ទៀងផ្ទាត់ ប្រៀបធៀប ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយនេះ ។

**៤. កុមាររស់នៅតាមទីវត្តអារាម និង នៅតាមទីកន្លែងជំនឿសាសនានានា**

ក. បង្កើតក្របខ័ណ្ឌគោលនយោបាយ សំរាប់គ្រប់គ្រង និង ធ្វើអោយទៅជាផ្លូវការនូវការថែទាំកុមារ នៅតាមទីវត្តអារាម និង នៅតាមទីកន្លែងជំនឿសាសនាផ្សេងៗ រួមមាន លទ្ធភាពទទួលបាន តួនាទី ការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និង គោលការណ៍ណែនាំ ដោយសហការជាមួយ ក្រសួងធម្មការ និង សាសនា ។

ខ. នៅក្នុងក្របខ័ណ្ឌគោលនយោបាយនេះ លើកស្ទួយការថែទាំនៅតាមទីវត្តអារាម និង នៅតាមទីកន្លែងជំនឿសាសនាផ្សេងៗ នៅតាមកម្មវិធីរបស់រដ្ឋ តាមកម្មវិធីអង្គការក្រៅរដ្ឋាភិបាល និង អាចារ្យវត្ត រួមមាន តាមរយៈការផ្តល់ការគាំទ្រផ្ទាល់ចំពោះការថែទាំ និង ការអប់រំកុមារ ។

គ. រៀបចំអោយទៅជាផ្លូវការ បង្កើត និង ពិនិត្យ តាមដានបទដ្ឋាននានា ផ្អែកលើក្របខ័ណ្ឌគោលនយោបាយ ។

ឃ. បង្កើតយន្តការអភិបាលកិច្ច និង យន្តការផ្តល់កិច្ចការពារនៅតាមទីវត្តអារាម និងនៅតាមទីកន្លែងជំនឿសាសនានានា ដោយប្រកាន់យករចនាសម្ព័ន្ធ និង ការទទួលខុសត្រូវ ជាលក្ខណៈវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។

ង. កសាងសមត្ថភាពរបស់បណ្តាអ្នកចូលរួមចំណែក រួមមាន ព្រះសង្ឃ ដូនជី លោកអាចារ្យ អ្នកគោរពសាសនាផ្សេងៗទៀត មន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងមន្ត្រីក្រសួងពាក់ព័ន្ធឯទៀតៗ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ក្រុង និង ថ្នាក់ស្រុក ខណ្ឌ ព្រមទាំង មន្ត្រីដែលជាអ្នកផ្តល់សេវាថែទាំជំនួស ដោយផ្តោតលើការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយនេះ ។

ច. មុនពេលបញ្ជូនកុមារអោយទៅទទួលការថែទាំនៅតាមទីវត្តអារាម ឬ នៅតាមទីកន្លែងជំនឿសាសនានានាទៀត ត្រូវស្តាប់កុមាររួចប្រាប់កុមារអោយដឹងពីទីកន្លែង ដែលកុមារត្រូវទៅរស់នៅ ( សិទ្ធិ និង ការទទួលខុសត្រូវរបស់ទីវត្តអារាម ក៏ដូចជា របស់កុមារ ) ហើយ ទីវត្តអារាម និង កន្លែងផ្សេងៗទៀត ត្រូវមានលក្ខណៈសមស្របទៅតាមលក្ខណៈវិនិច្ឆ័យ ដែលក្របខ័ណ្ឌគោល

នយោបាយនេះ បានកំណត់ ។

ឆ. ពិនិត្យឡើងវិញនូវករណីមុនៗ ដែលកុមារបានរស់នៅតាមទីវត្តអារាម និង ទីកន្លែងជំនឿសាសនាផ្សេងៗទៀត ដោយផ្ទៀងផ្ទាត់ ប្រៀបធៀប ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយនេះ ។

**៥. កុមាររស់នៅតាមគ្រួសារ ឬ ផ្ទះដែលមានកុមារជាមេគ្រួសារ**

ក. បង្កើតក្របខ័ណ្ឌគោលនយោបាយ សំរាប់គ្រប់គ្រង និង ធ្វើអោយទៅជាផ្លូវការនូវការថែទាំកុមារនៅក្នុងគ្រួសារ ដែលមានកុមារជាមេគ្រួសារ រួមមាន លទ្ធភាពទទួលបានតួនាទី ការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និងគោលការណ៍ណែនាំ ។ ត្រូវមានខ្លឹមសារចែងដោយឡែក ដើម្បីធានាអោយកុមារនៅក្នុងគ្រួសារ ដែលមានកុមារជាមេគ្រួសារ មានលទ្ធភាពទទួលបានមរតក ។

ខ. ផ្តល់យន្តការនៃការគាំទ្រគ្រប់គ្រាន់ចំពោះក្រុមគ្រួសារមានស្រាប់ ដែលមានកុមារជាមេគ្រួសារ ។

គ. ដាក់កុមារអោយទទួលការថែទាំសមស្របដោយប្រកាន់យកទស្សនៈរបស់កុមារ និង ផ្តល់ពត៌មានដល់កុមារអោយដឹងពីទីកន្លែង ដែលកុមារត្រូវទៅរស់នៅ ( សិទ្ធិ និង ការទទួលខុសត្រូវរបស់ក្រុមគ្រួសារ ក៏ដូចជា របស់កុមារ ) ។

ឃ. រៀបចំអោយទៅជាផ្លូវការ បង្កើត និង ពិនិត្យ តាមដានបទដ្ឋាននានា ផ្អែកលើក្របខ័ណ្ឌគោលនយោបាយនេះ ។

ង. បង្កើតយន្តការអភិបាលកិច្ច និង យន្តការផ្តល់កិច្ចការពារនៅតាមសហគមន៍សំរាប់កុមារ ដែលរស់នៅតាមគ្រួសារ ដែលមានកុមារជាមេគ្រួសារដោយប្រកាន់យកនូវវចនាសម្ព័ន្ធ និងការទទួលខុសត្រូវជាលក្ខណៈវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។

ច. កសាងសមត្ថភាព មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង មន្ត្រីក្រសួងពាក់ព័ន្ធឯទៀតៗ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌ មន្ត្រីដែលជាអ្នកផ្តល់សេវាថែទាំជំនួសដោយផ្តោតលើការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយនេះ ។

ឆ. មុនពេលបញ្ជូនកុមារអោយទៅទទួលការចិញ្ចឹមថែទាំនៅក្នុងគ្រួសារដែលមានកុមារជាមេគ្រួសារត្រូវស្តាប់តាមកុមាររួចប្រាប់កុមារអោយដឹងពីទីកន្លែង ដែលកុមារត្រូវទៅរស់នៅ ( សិទ្ធិ និង ការទទួលខុសត្រូវរបស់គ្រួសារ ក៏ដូចជារបស់កុមារ ) ហើយ ក្រុមគ្រួសារត្រូវបំពេញអោយបានសមស្របទៅតាមលក្ខណៈវិនិច្ឆ័យ ដែលក្របខ័ណ្ឌគោលនយោបាយនេះ បានកំណត់ ។

ជ. ពិនិត្យឡើងវិញ នូវករណីមុន ៗ ដែលកុមារបានរស់នៅតាមគ្រួសារ ដែលមានកុមារជាមេគ្រួសារដោយផ្ទៀងផ្ទាត់ប្រៀបធៀបជាមួយនឹងក្របខ័ណ្ឌគោលនយោបាយនេះ។

## ៦. កុមាររស់នៅតាមមណ្ឌលស្តារនីតិសម្បទា មណ្ឌលកុមារកំព្រា និង កុមារទទួលបានការថែទាំនៅតាមផ្ទះជាក្រុម

ក. បង្កើតក្របខ័ណ្ឌគោលនយោបាយ សំរាប់គ្រប់គ្រង និង ធ្វើអោយទៅជាផ្លូវការនូវការថែទាំកុមារនៅក្នុងមណ្ឌលស្តារនីតិសម្បទា មណ្ឌលកុមារកំព្រា និង នៅតាមផ្ទះជាក្រុម រួមមាន លទ្ធភាពទទួលបានតួនាទី ការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និង គោលការណ៍ណែនាំ ។

ខ. លើកកំពស់ការយល់ដឹងស្តីពីសិទ្ធិកុមារ នៅតាមមណ្ឌលស្តារនីតិសម្បទា មណ្ឌលកុមារកំព្រា និង តាមផ្ទះជាក្រុមស្តីអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការថែទាំនៅតាមមណ្ឌលស្នាក់នៅយូរអង្វែង ។

គ. នៅក្នុងក្របខ័ណ្ឌការងារដែលមានស្រាប់ កាត់បន្ថយចំនួនកុមាររស់នៅតាមមណ្ឌលនានា និង នៅតាមមណ្ឌលកុមារកំព្រា តាមរយៈធ្វើការស្រាវជ្រាវ និង ធ្វើការបង្រួបបង្រួមកុមារទៅក្នុងក្រុមគ្រួសារវិញ និង ធ្វើសមាហរណកម្មកុមារអោយចូលទៅនៅក្នុងសហគមន៍វិញ ព្រមទាំងទទួលបានការថែទាំនៅតាមផ្ទះជាក្រុម ដោយចាត់ចែងទៅតាមលទ្ធភាព ដែលអាចធ្វើបានពីដំបូង ។

ឃ. បង្កើតគំរូថែទាំជំនួសតាមមណ្ឌលស្នាក់នៅយូរអង្វែង ។

ង. លើកទឹកចិត្តមណ្ឌលនានា និង មណ្ឌលកុមារកំព្រាអោយផ្តល់បរិយាកាសស្និទ្ធស្នាលតាមលទ្ធភាពអោយដូចជាជីវិតរស់នៅក្នុងគ្រួសារ និងនៅតាមសហគមន៍ ឧទាហរណ៍ដូចជា ការថែទាំនៅតាមផ្ទះជាក្រុម ការទំនាក់ទំនងទៅវិញទៅមកជាមួយសហគមន៍ ។

ច. រៀបចំអោយទៅជាផ្លូវការ បង្កើត និង ពិនិត្យ តាមដានបទដ្ឋាននានា ផ្អែកលើក្របខ័ណ្ឌគោលនយោបាយ ។

ឆ. បង្កើតយន្តការអភិបាលកិច្ច និង យន្តការផ្តល់កិច្ចការពារនៅតាមសហគមន៍សំរាប់កុមារដែលរស់នៅតាមមណ្ឌលស្តារនីតិសម្បទា មណ្ឌលកុមារកំព្រា និង តាមផ្ទះជាក្រុម ដោយប្រកាន់យករចនាសម្ព័ន្ធ និង ការទទួលខុសត្រូវជាលក្ខណៈវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។

ជ. កសាងសមត្ថភាព មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង មន្ត្រីក្រសួងពាក់ព័ន្ធឯទៀតៗ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ក្រុង និង ថ្នាក់ស្រុក ខណ្ឌ មន្ត្រីដែលជាអ្នកផ្តល់សេវាថែទាំជំនួសដោយផ្តោតលើការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយនេះ ។

ឈ. មុនពេលបញ្ជូនកុមារអោយទៅទទួលការចិញ្ចឹមថែទាំនៅក្នុងមណ្ឌលស្តារនីតិសម្បទា មណ្ឌលកុមារកំព្រា និង តាមផ្ទះជាក្រុម ត្រូវស្តាប់កុមាររួចប្រាប់កុមារអោយដឹងពីទីកន្លែងដែលកុមារត្រូវទៅរស់នៅ (សិទ្ធិ និងការទទួលខុសត្រូវរបស់មណ្ឌលនានា មណ្ឌលកុមារកំព្រា ផ្ទះជាក្រុម ក៏ដូចជារបស់កុមារ) ហើយ មណ្ឌលស្តារនីតិសម្បទា មណ្ឌលកុមារកំព្រា និង ផ្ទះជាក្រុម ត្រូវបំពេញ

អោយបានសមស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលក្របខ័ណ្ឌគោលនយោបាយនេះ បានកំណត់ ។

កុមាររងគ្រោះផ្សេងៗទៀត ដែលមិនស្ថិតក្រោមរូបភាពនៃការថែទាំខាងលើ ក៏អាចត្រូវការការថែទាំជំនួសនៅពេលណាមួយផងដែរ ។ ទិសដៅជាក់លាក់សំរាប់កុមារជាប់ពន្ធនាគារ និង កុមារដែលមានទំនាស់ជាមួយច្បាប់ កុមារពិការអសមត្ថភាព និង កុមារដែលបានទទួលផលប៉ះពាល់ដោយសារមេរោគ និង ជំងឺអេដស៍ ត្រូវបានលើកឡើងនៅក្នុងចំនុចទី ៧ .៨ .៩ ចំពោះ និយមន័យ និង បញ្ហានានាដែលទាក់ទិនទៅនឹងភាពងាយរងគ្រោះទូលំទូលាយវិញ មានចែងក្នុងចំនុច VIII នៃគោលនយោបាយនេះ ។ ក្រៅពីគោលនយោបាយនេះ ចាំបាច់ត្រូវមានយុទ្ធវិធីផ្សេងទៀត ដើម្បីថែទាំកុមារពីព្រោះ កុមារទាំងនេះ អាចទទួលរងគ្រោះច្រើនលើកច្រើនសារដដែលៗ ហើយត្រូវការអន្តរាគមន៍ចំរុះវិស័យ ។

## ៧. កុមារមានទំនាស់ជាមួយច្បាប់

ក. បង្កើតក្របខ័ណ្ឌគោលនយោបាយ សំរាប់គ្រប់គ្រង និងធ្វើអោយទៅជាផ្លូវការនូវការថែទាំកុមារដែលមានទំនាស់ជាមួយច្បាប់ ហើយដែលកំពុងជាប់នៅក្នុងពន្ធនាគារ ឬ ជាប់នៅក្នុងមណ្ឌលអប់រំកែប្រែអនីតិជននានា រួមមាន លទ្ធភាព តួនាទី ការទទួលខុសត្រូវ បទដ្ឋាននៃការថែទាំ និង គោលការណ៍ណែនាំ ។

ខ. លើកកំពស់ការអភិវឌ្ឍន៍ប្រព័ន្ធតុលាការសមស្របសំរាប់អនីតិជន ឧទាហរណ៍ដូចជា មានអង្គភាពនគរបាលពិសេស សំរាប់ផ្តល់កិច្ចការពារដល់កុមារដែលមានទំនាស់ជាមួយច្បាប់ និង ទប់ស្កាត់ការប្រព្រឹត្តបទល្មើសផ្សេងៗ ដោយអនីតិជន និង មានតុលាការសំរាប់អនីតិជន ។

គ. រៀបចំអោយទៅជាផ្លូវការ បង្កើត និង ពិនិត្យ តាមដាន បទដ្ឋាននានាផ្អែកលើក្របខ័ណ្ឌគោលនយោបាយ និង ច្បាប់ ហើយនិង លិខិតូបករណ៍ច្បាប់នានារបស់ជាតិ និង អន្តរជាតិស្តីពីយុត្តិធម៌សំរាប់អនីតិជន ។

ឃ. បង្កើតយន្តការអភិបាលកិច្ច និងយន្តការផ្តល់កិច្ចការពារនៅតាមសហគមន៍ប្រឆាំងនឹងការធ្វើបាបព្រមទាំងការកេងប្រវ័ញ្ចលើកុមារ ដែលមានទំនាស់ជាមួយច្បាប់ ដោយប្រកាន់យករចនាសម្ព័ន្ធ និង ការទទួលខុសត្រូវបែបវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។ ប្រការនេះ ពាក់ព័ន្ធចំពោះតែកុមារដែលមានទំនាស់ជាមួយច្បាប់ ដែលតុលាការបានបង្វែរទៅជូនកម្មវិធីនានានៅតាមសហគមន៍ ឬ ដែលគ្រប់គ្រងចាត់ចែងដោយសហគមន៍តែប៉ុណ្ណោះ ។

ង. កសាងសមត្ថភាពមន្ត្រីតុលាការ មេធាវី មន្ត្រីឆ្មាំពន្ធនាគារ មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង មន្ត្រីក្រសួងពាក់ព័ន្ធឯទៀតៗ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ក្រុង និង ថ្នាក់ស្រុក ខណ្ឌ មន្ត្រីដែលជាអ្នកផ្តល់សេវាថែទាំជំនួសដោយផ្តោតលើការអនុវត្តន៍ និងការតាម

ដានក្របខ័ណ្ឌគោលនយោបាយនេះ ។

ច. លើកកំពស់ការយល់ដឹង ដែលពាក់ព័ន្ធទៅនឹងជំរើសផ្សេងៗ ជំនួសការដាក់អនីតិជន អោយជាប់ពន្ធនាគារ និង សិទ្ធិរបស់កុមារនៅក្នុងពន្ធនាគារ ឬ នៅក្នុងមណ្ឌលអប់រំកែប្រែអនីតិជននានា និង សិទ្ធិរបស់កុមារ ដែលមានទំនាស់ជាមួយច្បាប់ ។

ឆ. លើកកំពស់កម្មវិធីទប់ស្កាត់ និង កម្មវិធីអន្តរាគមន៍ទាន់ពេលវេលា ដោយដោះស្រាយការប្រព្រឹត្តបទឧក្រិដ្ឋ និង ការប្រព្រឹត្តបទឧក្រិដ្ឋ ម្តងហើយម្តងទៀត ដោយកុមារ ។

ជ. កុមារដែលមានទំនាស់ជាមួយច្បាប់ ត្រូវដាក់អោយបានទទួលការថែទាំសមស្របទៅតាមអាយុវ័យ និង មានបូរណភាពផ្នែកសីលធម៌ ផ្លូវចិត្ត និង កាយសម្បទា និង ត្រូវបានប្រាប់អោយដឹងអំពីទីកន្លែងដែលកុមារត្រូវទៅរស់នៅ ( សិទ្ធិ និង ការទទួលខុសត្រូវរបស់បុគ្គលិកនៃទីកន្លែង ឬ មណ្ឌលអប់រំកែប្រែអនីតិជន និង កម្មវិធីនៅតាមសហគមន៍ ក៏ដូចជា សិទ្ធិរបស់កុមារ ) ។

ឈ.កាត់បន្ថយចំនួនកុមាររស់នៅក្នុងពន្ធនាគារ ឬ នៅតាមមណ្ឌលអប់រំកែប្រែអនីតិជន ដោយលើកកំពស់អោយមានជំរើសផ្សេងៗ ជំនួសការដាក់អនីតិជនក្នុងពន្ធនាគារអោយបានឆាប់ទាន់ពេលវេលា ឧទាហរណ៍ដូចជា ធ្វើសមាហរណកម្មកុមារអោយចូលទៅរស់នៅតាមក្រុមគ្រួសារវិញ ឬ ក៏រៀបចំអោយកុមាររស់នៅក្នុងសហគមន៍ ។

ញ.លើកទឹកចិត្តកម្មវិធីនៃមណ្ឌលអប់រំកែប្រែអនីតិជន និង កម្មវិធីនានានៅតាមសហគមន៍ សំរាប់កុមារដែលមានទំនាស់ជាមួយច្បាប់ ដើម្បីផ្តល់បរិយាកាសអនុគ្រោះតាមលទ្ធភាព ដោយធ្វើសមាហរណកម្មអនីតិជនចូលទៅនៅតាមសហគមន៍ ជាពិសេស តាមរយៈការជួយគាំទ្រ ដល់ទំនាក់ទំនងជាមួយក្រុមគ្រួសារ និង ផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម និង គាំទ្រការអប់រំ ។

### ៨. កុមារពិការ

ក. លើកកំពស់ការយល់ដឹង ស្តីពីសិទ្ធិ និង សមត្ថភាពរបស់កុមារពិការ ។

ខ. លើកកំពស់កម្មវិធីទប់ស្កាត់ពិការភាពរបស់កុមារតូច ។

គ. បង្កើតក្របខ័ណ្ឌច្បាប់សំរាប់ជនពិការ រួមមាន កុមារពិការ ឧទាហរណ៍ដូចជា មានច្បាប់ស្តីពី "សិទ្ធិជនពិការ" [១៤] ។

ឃ.បង្កើនលទ្ធភាពកុមារពិការអោយទទួលបានសេវាស្តារនីតិសម្បទាជាពិសេសតាមរយៈការអភិវឌ្ឍន៍កម្មវិធីស្តារនីតិសម្បទានៅតាមសហគមន៍ ដោយធានាអោយ កុមារពិការស្ថិតនៅក្នុងសហគមន៍របស់ខ្លួនក្នុងពេលទទួលការគាំទ្រចាំបាច់ ។

ង. លើកស្ទួយការអប់រំក្នុង និង ក្រៅប្រព័ន្ធ សំរាប់កុមារពិការទាំងនៅ សាលាចំណេះទូទៅ សាលាពិសេស ថ្នាក់ពិសេស និង ទាំងនៅផ្ទះ ។

ច. កែលំអលទ្ធភាពទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារ និង សកម្មភាពរកចំណូល ដែល

ផ្តល់ផលប្រយោជន៍ដល់កុមារពិការ និង ក្រុមគ្រួសាររបស់គេ ។

**៩. កុមារទទួលផលប៉ះពាល់ ឬ ផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍**

ក. ដាក់បញ្ចូលជំនួយសំរាប់ជួយកុមារដែលទទួលផលប៉ះពាល់ ឬដែលផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ទៅក្នុងកម្មវិធី និងគោលនយោបាយស្តីពីការថែទាំជំនួស ដើម្បីចៀសវាងការមាក់ងាយ ។

ខ. លើកកំពស់ការយល់ដឹងរបស់សហគមន៍ ស្តីពីបញ្ហាប្រកាន់រើសអើង និង ការមាក់ងាយកុមារដែលទទួលផលប៉ះពាល់ ឬ ដែលមានផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍ រួមមាន ការអនុវត្តន៍ទំលាប់ប្រកាន់រើសអើង ដូចជា ក្នុងការទទួលមរតក និង កេរ្តិ៍តំណែលជាដើម ។

គ. បង្កើនលទ្ធភាពទទួលបានជំនួយផ្នែកអាហារូបត្ថម្ភ និង សុខភាព សំរាប់ជួយដល់កុមារដែលទទួលផលប៉ះពាល់ និង ដែលមានផ្ទុកមេរោគអេដស៍ឬមានជំងឺអេដស៍អោយបានរយៈពេលយូរអង្វែង។

ឃ. ធានាការគាំទ្រផ្នែកសង្គមកិច្ច សេដ្ឋកិច្ច ចំពោះកុមារដែលទទួលផលប៉ះពាល់ ឬ ដែលមានផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍ និង ក្រុមគ្រួសាររបស់កុមារ រួមមាន អន្តរាគមន៍ទាន់ពេលវេលាសំរាប់ជួយកុមារ ដែលមានឳពុកម្តាយផ្ទុកមេរោគអេដស៍ អោយមានលទ្ធភាពទទួលបាន ការផ្តល់ប្រឹក្សាការថែទាំជំនួស ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបានមរតក និង កេរ្តិ៍តំណែលមានលទ្ធភាពរកចំណូល និង ទទួលបានកិច្ចការពារ ។

## VII. ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល និង ការប្តេជ្ញាចិត្តរបស់មន្ត្រី និង ភ្នាក់ងារផ្តល់ការថែទាំជំនួស

**១. ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល**

ក. ពិនិត្យឡើងវិញ ការរៀបចំបង្កើត គោលនយោបាយ ច្បាប់ និង ចងក្រងលិខិតបទដ្ឋានផ្សេងៗទៀត អោយស្របទៅតាម អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីប្រកាសទីក្រុងស្តុកខុលស្តីពីកុមារ និង ការថែទាំតាមមណ្ឌលស្នាក់នៅយូរអង្វែង សេចក្តីប្រកាសស្តីពីគោលការណ៍សង្គម និង ច្បាប់នានា ដែលទាក់ទងទៅនឹងកិច្ចការពារ និង សុខុមាលភាពរបស់កុមារ ហើយដែលមានខ្លឹមសារពិសេសពាក់ព័ន្ធទៅនឹងការរៀបចំកុមារអោយគេចិញ្ចឹមជាកូនធម៌ និង ជាកូនចិញ្ចឹមក្នុងប្រទេស និង ក្រៅប្រទេស[xi] គោលការណ៍សហប្រជាជាតិ សំរាប់ការពារអនីតិជន ដែលត្រូវបានគេដកហូតសេរីភាព[xii] និង លិខិតតូបករណ៍ច្បាប់អន្តរជាតិពាក់ព័ន្ធនានា ។

ខ. ផ្សព្វផ្សាយ និង ធានាការអនុវត្តន៍ គោលនយោបាយ ច្បាប់ និងឯកសារពាក់ព័ន្ធឯទៀតអោយមានប្រសិទ្ធភាព ។

គ. ដឹកនាំការបង្កើត និង អនុមត័បទដ្ឋានអប្បបរិមា និង គោលការណ៍ណែនាំស្តីពីការថែទាំជំនួស ។

ឃ. ផ្អែកតាមការអនុវត្តន៍បទដ្ឋានអប្បបរិមា និង គោលការណ៍ណែនាំជាធរមាន ពិនិត្យ តាមដាន វាយតំលៃ និង ផ្តល់ការអនុញ្ញាត ដល់អ្នកផ្តល់សេវាថែទាំជំនួស របស់រដ្ឋ និង របស់អង្គការក្រៅរដ្ឋាភិបាល នានា ។

ង. បែងចែកថវិកា សំរាប់ឧបត្ថម្ភដល់ការងារថែទាំជំនួស ស្របតាមចំនួនអ្នកទទួលផល គោលនយោបាយជាតិ បទដ្ឋានអប្បបរិមា និង គោលការណ៍ណែនាំ ដោយផ្តោតការយកចិត្តទុកដាក់ពិសេស ទៅលើតួនាទីរបស់មន្ត្រីរាជការក្នុងការប្រតិបត្តិ ពិនិត្យ តាមដាន និង វាយតំលៃ កម្មវិធីថែទាំជំនួស។

ច. បង្កលក្ខណៈងាយស្រួល ជួយភ្នាក់ងារផ្តល់សេវាថែទាំជំនួសរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការគៀងគររកថវិកា និង ជួយរកដំណោះស្រាយ និង ការអនុវត្តន៍ប្រកបដោយនិរន្តរភាព ។

ឆ. ដឹកនាំសំរបសំរួល និង ផ្តល់កិច្ចសហប្រតិបត្តិការដល់ដៃគូផ្តល់ជំនួយ ។

## ២. ការប្តេជ្ញាចិត្តរបស់មន្ត្រី និង ភ្នាក់ងារផ្តល់ការថែទាំជំនួស

ក. សហការជាមួយស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ជួយពិនិត្យឡើងវិញ ការរៀបចំ និង ផ្សព្វផ្សាយ គោលនយោបាយ ច្បាប់ បទដ្ឋានអប្បបរិមា និង គោលការណ៍ស្តីពីការថែទាំជំនួស អោយស្របទៅតាម អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីប្រកាសទីក្រុងស្តុកខុលស្តីពីកុមារ និង ការថែទាំតាមមណ្ឌលស្នាក់នៅយូរអង្វែង ហើយនិង គោលការណ៍នានារបស់អនុសញ្ញា និង សេចក្តីប្រកាស ។

ខ. អនុវត្តគោលនយោបាយ ច្បាប់ បទដ្ឋានអប្បបរិមា និងគោលការណ៍ណែនាំស្តីពីការថែទាំជំនួស។

គ. ពិនិត្យ តាមដាន និង វាយតំលៃសកម្មភាពការងារផ្ទាល់ខ្លួន ផ្តល់របាយការណ៍ ព្រមទាំងជួយសំរួលដល់ការ ពិនិត្យ តាមដាន និង ការវាយតំលៃ ដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អោយសមស្របទៅតាម គោលនយោបាយ បទដ្ឋានអប្បបរិមា និង គោលការណ៍ណែនាំស្តីពីការថែទាំជំនួស ។

ឃ. សុំការអនុញ្ញាតនិងចុះកិច្ចព្រមព្រៀង ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា។

ង. គៀងគររកថវិកាអោយបានគ្រប់គ្រាន់ សំរាប់ឧបត្ថម្ភអ្នកទទួលផល និង បែងចែកថវិកាឧបត្ថម្ភដល់កម្មវិធីនានា អោយស្របទៅតាម គោលនយោបាយជាតិ បទដ្ឋានអប្បបរិមា និង គោលការណ៍ណែនាំ ។

ច. ជួយអភិវឌ្ឍ និង អនុវត្តដំណោះស្រាយប្រកបដោយនិរន្តរភាព ដោយយកចិត្តទុកដាក់ពិសេសទៅ

លើការលើកស្ទួយដំណោះស្រាយនានានៅតាមគ្រួសារ និង សហគមន៍ ។

ឆ. ជួយលើកស្ទួយគោលការណ៍ស្តីពីការថែទាំជំនួស តាមរយៈគោលនយោបាយសំរាប់បុគ្គលិក ( តួនាទី ការទទួលខុសត្រូវ ការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល បៀវត្សរ៍ និងការគ្រប់គ្រង ) និង គោលនយោបាយទាក់ទងដល់ការទទួលយកកុមារមកចិញ្ចឹមថែទាំ (ក្រុមគោលដៅ លក្ខណៈវិនិច្ឆ័យ និង និតិវិធីផ្សេងៗ ) ។

ជ. ចូលរួមចំណែកក្នុងការសំរបសំរួលនានា ជាមួយបណ្តាអង្គការសង្គមស៊ីវិល និង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

## VIII. និយមន័យ និង បញ្ហាពាក់ព័ន្ធនៅនឹងប្រភេទពិសេសនៃភាពងាយរងគ្រោះ

មានបរិបទជាច្រើន ដែលអាចធ្វើអោយមានគ្រោះថ្នាក់ដល់កុមារដែលត្រូវការ ការថែទាំជំនួស ។ ស្ថានភាពខ្លះ អាចធ្វើអោយកុមារងាយរងគ្រោះ ដោយសារតែ ពុំមានឪពុកម្តាយ ឬ អ្នកអាណាព្យាបាលនៅជាមួយ ឬ ក៏ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ពុំអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន ឧទាហរណ៍ កុមារកំព្រា កុមារញៀនសារធាតុញៀន និង កត្តាផ្សេងៗទៀត ដែលអាចធ្វើអោយបាត់បង់អំណាចមេបា ឬ ក៏ ត្រូវអាជ្ញាធរមានសមត្ថកិច្ចដកអំណាចមេបា ។

### ១. កុមារកំព្រា

និយមន័យរបស់ពាក្យថា កុមារកំព្រា គឺ " កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ ហើយដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ បានទទួលមរណៈភាព "[ខ] ។

យោលទៅតាមនិយមន័យនេះ ចំនួនសរុបនៃកុមារកំព្រា គឺជាចំនួនកុមារដែលកំព្រាម្តាយ និងកុមារកំព្រាឪពុក ដកចេញកុមារកំព្រា ទាំងឪពុក ទាំងម្តាយ ដែលគេបានរាប់បញ្ចូលក្នុងក្រុមទាំងពីរខាងលើ ។

### ២. កុមារមានទំនាស់ជាមួយច្បាប់

កុមារមានទំនាស់ជាមួយច្បាប់ គឺជាកុមារដែលត្រូវបានសង្ស័យ ត្រូវបានចោទប្រកាន់ ឬ ត្រូវបានកាត់អោយជាប់ទោសពីបទបានប្រព្រឹត្តបទឧក្រិដ្ឋ ( មិនថាជាបទល្មើសកំរិតធ្ងន់ ឬ បទល្មើសមជ្ឈឹមនោះឡើយ ) ។ កុមារដែលមានទំនាស់ជាមួយច្បាប់ ហើយដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ ឬ ត្រូវបានដាក់នៅក្នុងមណ្ឌលអប់រំកែប្រែអនីតិជន អាចជា កុមារដែលត្រូវបានឃុំខ្លួនមុនកាត់ទោស (ជាកុមារដែលត្រូវបានបញ្ជូនត្រឡប់មកឃុំខ្លួនវិញរង់ចាំការកាត់ទោស ) ឬជាកុមារដែលត្រូវបានកាត់ទោសរួចហើយ ។ ដោយសារតែ មានការខ្វះខាតមណ្ឌលអប់រំកែប្រែអនីតិជន កុមារមួយចំនួនដែលត្រូវបានកាត់អោយជាប់ទោស ឬ ដែលត្រូវបានបញ្ជូនត្រឡប់មកឃុំខ្លួនវិញ រង់ចាំការកាត់ទោស ត្រូវបានឃុំខ្លួនរួមគ្នាជាមួយនឹង

អ្នកទោស ដែលជាមនុស្សពេញវ័យដែរ ។ ការឃុំកុមារបែបនេះ ធ្វើអោយប៉ះពាល់ដល់សិទ្ធិកុមារក្នុងការទទួលបានការថែទាំសមស្រប ។

## ៣. កុមាររស់នៅក្នុងគ្រួសារក្រីក្រ

គ្រួសារដែលក្រីក្របំផុត ពុំមានលទ្ធភាពផ្តល់ការថែទាំសមស្របសំរាប់កុមារនៅក្នុងគ្រួសាររបស់ខ្លួនទេ ។ នៅពេលជួបប្រទះបញ្ហា ដូចជា បញ្ហាសុខភាព គ្រោះថ្នាក់ផ្សេងៗ អាចធ្វើអំពើអ្វីមួយមិនសមស្របចំពោះកូន ដូចជា បោះបង់ចោល ធ្វើអាជីវកម្មកុមារជាកូនរបស់ខ្លួន លក់ ឬ ជួលទៅអោយអ្នកជួញដូរ ។ ក្នុងករណីនេះ កុមារអាចរត់គេចពីផ្ទះ ។

## ៤. កុមារពិការ

" ជនពិការសំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាត សរីរាង្គណាមួយ ឬ សតិបញ្ញា បណ្តាលអោយមានការរំខានដល់ជីវភាពរស់នៅ ឬ សកម្មភាពនានាប្រចាំថ្ងៃ ដូចជា ជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា និង ប្រភេទពិការផ្សេងៗទៀត ដែលនាំអោយមានលក្ខណៈមិនប្រក្រតី និង មានលិខិតបញ្ជាក់ចេញដោយ ក្រសួងទទួលបន្ទុកវិស័យសុខាភិបាល "[៦៦] ។ អង្គការសុខភាពពិភពលោកបានអោយនិយមន័យ ពិការភាព គឺជាការមានកំរិត ឬ ខ្វះលទ្ធភាពដោយសារតែ ជនពិការមិនអាចធ្វើអ្វីមួយបានប្រចាំថ្ងៃដូចមនុស្សធម្មតា ។ ប្រភេទនៃពិការភាពទាក់ទងទៅនឹងអាកប្បកិរិយាប្រព្រឹត្ត ការប្រាស្រ័យទាក់ទង ការថែទាំខ្លួន ការចល័ត ភាពប៉ិនប្រសប់ និង មុខជំនាញពិសេស ។ ពាក់ព័ន្ធទៅនឹងការថែទាំជំនួស ជាទូទៅ កុមារពិការអសមត្ថភាពតែងតែ ទទួលបានការថែទាំនៅតាមមណ្ឌល ព្រោះម្យ៉ាងដោយសារកុមារពិការជាមនុស្សដែលងាយត្រូវបោះបង់ចោល ហើយមិនសូវមានក្រុមគ្រួសារ ឬសហគមន៍គិតគូរយកមកអោយរស់នៅ និង ផ្តល់ការថែទាំនោះឡើយ ។

## ៥. កុមារទទួលផលប៉ះពាល់ ឬ ផ្ទុកមេរោគអេដស៍ ឬ មានជំងឺអេដស៍

ទោះជា មានកុមារត្រឹមមួយចំនួនតូចប៉ុណ្ណោះ ទទួលរងផលប៉ះពាល់ពី មេរោគអេដស៍ ឬ ជំងឺអេដស៍ ប៉ុន្តែ ការឆ្លងរាលដាលនៃមេរោគ និង ជំងឺអេដស៍ និង ការស្លាប់បាត់បង់ជីវិតរបស់ឪពុកម្តាយដោយសារមេរោគ និង ជំងឺអេដស៍ កំពុងតែបង្កអោយមានការកើនឡើង នូវចំនួនកុមារកំព្រា និង កុមាររស់នៅក្នុងក្រុមគ្រួសារដែលមានកុមារជាមេគ្រួសារ ។ ទោះបីជា ឪពុកម្តាយនៅមានជីវិតរស់នៅឡើយក៏ដោយ ក៏ការចំណាយទៅលើបញ្ហាសុខភាពបានប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ក្រុមគ្រួសារ ហើយកុមារដែលថែទាំឪពុកម្តាយឈឺ អាចនឹងបោះបង់សាលារៀនផងដែរ ។ ម្យ៉ាងទៀត សេចក្តីត្រូវការខាងផ្លូវចិត្ត និង

អារម្មណ៍របស់កុមារ ដែលបានទទួលផលប៉ះពាល់ ដោយសារ មេរោគ និង ជំងឺអេដស៍ មានច្រើន ដូច សេចក្តីត្រូវការខាង ការហូបចុក ការអប់រំ ការថែទាំសុខភាព ឬ ជំរក....។ ដើម្បីអោយកុមារដែលបាន ទទួលផលប៉ះពាល់ដោយសារមេរោគ និងជំងឺអេដស៍ មានឱកាសល្អៗ ដូចគ្នានឹងកុមារឯទៀតៗដែរនោះ ចាំបាច់ត្រូវទទួលស្គាល់សេចក្តីត្រូវការទាំងនេះ ។ វិធីដោះស្រាយនានា នៅតាមសហគមន៍មានប្រសិទ្ធិ ភាពណាស់ក្នុងការបង្កើតជាបណ្តាញសុវត្ថិភាព និង ការគាំទ្រចំពោះករណីមួយចំនួនធំ ប៉ុន្តែ ជាចាំបាច់ គឺត្រូវពង្រឹងយុទ្ធសាស្ត្រពាក់ព័ន្ធនានា ។

## ៦. កុមារទទួលផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារ

កុមារដែលទទួលផលប៉ះពាល់ ដោយសារអំពើហិង្សាក្នុងគ្រួសារ អាចមានអារម្មណ៍ពាក់ព័ន្ធគ្នាជា មួយនឹងអាកប្បកិរិយា ដូចជា ÷

- ភ័យខ្លាចពេលឃើញឪពុកម្តាយឈ្លោះប្រកែកគ្នាម្តងៗ
- គ្មានអំណាចឥទ្ធិពល និង គិតថាខ្លួនមានពិរុទ្ធ ដោយសារខ្លួនពុំមានលទ្ធភាពបញ្ឈប់ អំពើហិង្សា ដែលខ្លួនបានឃើញជាក់ស្តែងនោះបាន
- បាត់បង់ការផ្តោតអារម្មណ៍រៀនសូត្រនៅសាលារៀន
- អាចប្រព្រឹត្តអំពើហិង្សា ដោយធ្វើតាមអ្វី ៗ ដែលបានសង្កេតឃើញនៅផ្ទះ
- ចិត្តមិនស្ងប់
- យល់សុបិនអាក្រក់ ដេកពុំលក់
- ក្រៀមក្រំ និង ធ្លាក់ទឹកចិត្ត ។

អំពើហិង្សាក្នុងគ្រួសារ គឺជាមូលហេតុច្រើនដែលធ្វើអោយកុមាររត់ចេញពីផ្ទះហើយក៏អាចជាបញ្ហា នាំអោយអាជ្ញាធរនានា ដកសិទ្ធិអំណាចមេបា និង ផ្ទេរសិទ្ធិអំណាចនេះ ទៅអោយអ្នកដទៃជាអ្នកថែទាំ ជំនួសវិញផងដែរ ។

## ៧. កុមារទទួលផលប៉ះពាល់ដោយសារធាតុញៀន និង អំពើអបាយមុខ

ការញៀន និង អំពើអបាយមុខ នៅក្នុងគ្រួសារ ទោះជា គ្រឿងស្រវឹង ថ្នាំញៀន ឬ ជាល្បែងស៊ី សងក៏ដោយ ក៏ធ្វើអោយកុមារមានគ្រោះថ្នាក់បានដែរតាមរូបភាពជាច្រើន ។ ការញៀន ទោះជា មនុស្ស ពេញវ័យ ទោះជា កុមារក៏ដោយ ក៏វានៅតែប៉ះពាល់ដល់សុខភាពដូចគ្នាដែរ ហើយព្រមទាំង បង្កអោយ មានការញៀនផ្នែករាងកាយ ដែលភាគច្រើនៗតែ ធ្វើអោយខូចដល់ផ្លូវចិត្ត និង កាយ ។ ដូចជា ស្រា ឬ ថ្នាំញៀន ការលេងល្បែងស៊ីសង ក៏នាំអោយមនុស្សញៀនដែរ ហើយ បានធ្វើអោយក្រុមគ្រួសារទាំងមូល ធ្លាក់ខ្លួនជំពាក់បំណុលគេជាច្រើនលើកច្រើនគ្រាបន្តបន្ទាប់គ្នា ដែលជាការប៉ះពាល់ដល់ជីវភាពរស់នៅ

និង ប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ ។ ស្រា ថ្នាំញៀន និង ការលេងល្បែងស៊ីសង អាចបង្កអោយមាន ជំលោះ និង អំពើហឹង្សាក្នុងគ្រួសារ ដែលគំរាមកំហែងសមាជិកគ្រួសារទាំងមូល ។ លើសពីនេះទៀត ស្ថានភាពបែបនេះ អាចបង្កអោយគ្រួសារទាំងមូលបញ្ចាំ ឬ លក់ដូរមធ្យោបាយបង្កបង្កើតផល ដើម្បី បំពេញសេចក្តីត្រូវការនៃការញៀន ដែលរឹងរឹតតែធ្វើអោយអន្តរាយថែមទៀតដល់ជីវភាពរស់នៅរបស់ គ្រួសារ ។ ក្នុងករណីនេះ ឪពុកម្តាយអាចឈានទៅលក់ កូនបង្កើតរបស់ខ្លួន ។

## ៨. កុមារអនាថាតាមចិញ្ចើមថ្នល់

ពាក្យថា កុមារអនាថាតាមចិញ្ចើមថ្នល់គ្របដណ្តប់ស្ថានភាពផ្សេងៗ គ្នាជាច្រើន ÷

- កុមារដែលរស់នៅតាមចិញ្ចើមថ្នល់ ជាទូទៅ ច្រើនតែផ្តាច់ការទាក់ទង ជាមួយក្រុមគ្រួសាររបស់ខ្លួន និង រស់នៅដោយគ្មានអ្នកគ្រប់គ្រងនៅតាមចិញ្ចើមថ្នល់ ។
- កុមារធ្វើការងារនៅតាមចិញ្ចើមថ្នល់ បានចំណាយពេលវេលាយ៉ាងច្រើននៅតាមចិញ្ចើមថ្នល់ ដើម្បី រកប្រាក់ផ្តល់អោយក្រុមគ្រួសាររបស់ខ្លួន ឬ សំរាប់ផ្គត់ផ្គង់ខ្លួនឯង ។ ជាទូទៅ កុមារអនាថាតាមចិញ្ចើមថ្នល់ប្រភេទនេះ តែងតែវិលត្រឡប់ទៅផ្ទះវិញនៅពេលយប់។
- កុមារ ដែលជាកូនចៅរបស់ក្រុមគ្រួសាររស់នៅតាមចិញ្ចើមថ្នល់ តែងតែរស់នៅ ជាមួយក្រុមគ្រួសាររបស់គេនៅតាមចិញ្ចើមថ្នល់ ។

មូលហេតុដែលនាំអោយពួកគេមករស់នៅតាមចិញ្ចើមថ្នល់ គឺភាពក្រីក្រនៅទីជនបទ អំពើហឹង្សាក្នុងគ្រួសារ ឬ ការរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជាដើម ។

កុមារអនាថា ទោះជា មានការគាំទ្រតាមកំរិត ដែលឪពុកម្តាយបានផ្តល់អោយក៏ដោយ ក៏កុមារទាំងអស់នោះ អាចទទួលផលប៉ះពាល់ផ្ទាល់ និង មានគ្រោះថ្នាក់ ខាងរូបរាងកាយ និង ផ្លូវចិត្តដែរ ដែលក្នុងនោះ រួមមាន អំពើហិង្សា ការលេងល្បែងស៊ីសង ការប្រព្រឹត្តបទល្មើសផ្សេងៗ ការញៀន ការជួញដូរ និង ពេស្យាចារ ដែល ចាំបាច់ត្រូវពិនិត្យពិចារណា ដើម្បីកំណត់អន្តរាគមន៍អោយមានប្រសិទ្ធភាព ។

## ៩. កុមារត្រូវបានរំលោភបំពាន

កុមារត្រូវបានរំលោភបំពានរួមមាន ÷

- កុមារា ឬ កុមារី ត្រូវបានធ្វើបាបធ្ងន់ធ្ងរលើរូបរាងកាយ ឬ ផ្លូវអារម្មណ៍ ។
- កុមារា ឬកុមារី គឺជាជនរងគ្រោះដោយសារអំពើរំលោភធ្វើបាបផ្លូវភេទ ដូចជា ករណីរំលោភសេពសន្ថវៈ សន្ទនការ ការបង្ហាញក្តៅខ្មាសដល់កុមារ ឬ ទំនាក់ទំនងផ្លូវភេទជាមួយមនុស្សពេញវ័យ ។ ការដែលមនុស្សពេញវ័យចូលចិត្តរួមរក្សជាមួយកុមារ និង ការប្រព្រឹត្តអំពើអនា

ចារ គឺជា រូបភាពនៃការរំលោភផ្លូវភេទមួយ ដែលមានមនុស្សពេញវ័យជាអ្នក ប្រព្រឹត្តទៅលើកុមារអាយុពុំទាន់ពេញវ័យ ។

ការរំលោភបំពានលើកុមារ ជាមូលហេតុមួយ ដែលច្រើនធ្វើអោយកុមាររត់ចេញពីផ្ទះ ហើយក៏អាចជាបញ្ហានាំអោយអាជ្ញាធរនានាដកសិទ្ធិអំណាចមេបា ពីឪពុកម្តាយ ហើយ ផ្ទេរសិទ្ធិអំណាចនេះ ទៅអោយអ្នកដទៃជាអ្នកថែទាំជំនួសវិញផងដែរ ។

## ១០. កុមារត្រូវបានកេងប្រវ័ញ្ច

កុមារត្រូវបានកេងប្រវ័ញ្ចរួមមាន ៖

- កុមារា ឬ កុមារី ជាជនរងគ្រោះនៃអំពើកេងប្រវ័ញ្ចផ្លូវភេទ ដូចជា ក្នុងករណី ពេស្យាចារ ឬ ការពាក់ព័ន្ធក្នុងអាជីវកម្មរូបអាសអាភាស ។ ការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ គឺ សំដៅលើមនុស្សពេញវ័យ ដែលប្រើប្រាស់ផ្លូវភេទកុមារ ដោះដូរជាមួយ នឹងប្រាក់កាស ឬ របស់របរ ជាមួយ កុមារផ្ទាល់ ឬ ជាមួយមនុស្សទីបីណាម្នាក់ ។
- ពលកម្មកុមារ គឺ សំដៅលើរយៈពេលដែលកុមារ ធ្វើការងារច្រើនម៉ោងក្នុងមួយថ្ងៃៗ ប៉ុន្តែទទួលបានប្រាក់កំរៃតិចក្រោមលក្ខខណ្ឌការងារ ដែលអាចបង្កគ្រោះថ្នាក់ ដល់ការអភិវឌ្ឍន៍រូបរាងកាយ និង ផ្លូវចិត្តរបស់កុមារ ដែលរារាំងកុមារមិនអោយទទួលបានការអប់រំរៀនសូត្រ ។ ការងារបែបនេះ ត្រូវចាត់ទុកថា មានផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ រូបរាងកាយ បញ្ញា ផ្លូវចិត្ត និង សង្គមរបស់កុមារ ។ ការងារនេះ ធ្វើអោយកុមារ បែក ពីក្រុមគ្រួសារ និង ប៉ះពាល់ ដល់អនាគតរបស់កុមារ ។ ( មានចែងក្នុងអនុសញ្ញាលេខ១៨២របស់អង្គការពលកម្មអន្តរជាតិ និងប្រកាសលេខ ១០៦ សកបយ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់ ) ។
- កុមារា ឬ កុមារី ត្រូវបានកេងប្រវ័ញ្ចពលកម្ម រួមមាន កុមារដែលមិនត្រូវបានអនុញ្ញាតិអោយរៀនសូត្រដើម្បីអោយធ្វើការនៅតាមស្រែ ចំការ ឬ ធ្វើការងារក្នុងផ្ទះអោយសាច់ញាតិ ជាដើម ។ ដូចគ្នានឹង នៅតាមបណ្តាប្រទេសជាច្រើនដែរ គឺ ប្រពៃណី និង ទំនៀមទំលាប់របស់កម្ពុជា ច្រើនអនុគ្រោះ ហើយលើកទឹកចិត្តដល់កុមារ ដែលរួមចំណែកជួយដល់ការងារក្នុងផ្ទះ ឬ នៅផ្ទះ ។ ការរួមចំណែកដល់ជីវភាពរស់នៅរបស់គ្រួសារបែបនេះ ត្រូវទទួលបានការសរសើរ និង ជាផ្នែកមួយដ៏សំខាន់សំរាប់កុមារចូលរួម និង យល់ដឹងពីសង្គមជាតិ និង ជាមធ្យោបាយមួយដើម្បីផ្ទេរជំនាញ ដែលទទួលបានពីមនុស្សជំនាន់មួយទៅជំនាន់មួយទៀត ។

ករណីនេះ មិនចាត់ទុកជាអំពើកេងប្រវ័ញ្ចពលកម្មកុមារទេ ល្គឹកណា កុមារបានទទួលការអប់រំរៀនសូត្រ និង មិនប៉ះពាល់ការអភិវឌ្ឍន៍ រូបរាងកាយ បញ្ញា ផ្លូវចិត្ត និង សង្គមរបស់កុមារ ។

- កុមារា កុមារី ត្រូវបានជួញដូរ ។ ការជួញដូរ គឺជា " ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជំរកលាក់ខ្លួន ឬ ការទទួលមនុស្សដោយប្រើមធ្យោបាយគំរាមកំហែង ដោយការប្រើប្រាស់កំលាំង ឬ ការប្រើប្រាស់ទម្រង់ផ្សេងៗទៀត នៃការបង្ខិតបង្ខំ ដូចជា ការចាប់ពង្រត់ ការឆបោក ការបំភ័ន្តបោកប្រាស់ ការរំលោភបំពានដោយអំណាច ឬ លើស្ថានភាពដែលងាយរងគ្រោះ ឬ ការប្រគល់ ឬ ទទួលប្រាក់ ឬ ផលប្រយោជន៍ផ្សេងៗ ដើម្បីទទួលបានការយល់ព្រម ពីជនណាម្នាក់ដែលគ្រប់គ្រងលើមនុស្សម្នាក់ទៀត ក្នុងគោលបំណងធ្វើការកេងប្រវ័ញ្ច ។ ការកេងប្រវ័ញ្ច រួមមាន ការកេងប្រវ័ញ្ចអ្នកដទៃ តាមរយៈ ពេស្យាចារ ឬ ទម្រង់ផ្សេងៗទៀត នៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មបង្ខិតបង្ខំ ឬ សេវាបង្ខិតបង្ខំ ទាសករដាច់ថ្លៃ ឬ ការអនុវត្តន៍នានា ដែលមានលំនាំ ដូចជា ទាសករដាច់ថ្លៃ សេវគតិភាព ឬ ការកាត់យក សរីរាង្គណាមួយ ។ ករណីខាងលើនេះ ទោះបីមានការយល់ព្រមរបស់ជនរងគ្រោះក៏ដោយ ក៏ចាត់ទុកជា អំពើជួញដូរកុមារ ដែរ "[២២] ។

អំពើកេងប្រវញ្ចកុមារ ជាមូលហេតុមួយ ធ្វើអោយកុមាររត់ចេញពីផ្ទះ ហើយក៏ អាចជាបញ្ហានាំអោយអាជ្ញាធរដកសិទ្ធិអំណាចមេបា ពី ឪពុកម្តាយ ហើយ ផ្ទេរសិទ្ធិអំណាចនេះ ទៅអោយអ្នកដទៃជាអ្នកថែទាំជំនួសវិញផងដែរ ។

**រដ្ឋមន្ត្រី**

អង្គការយូនីសេហ្វ (២០០៤)។ របាយការណ៍ប្រចាំឆ្នាំ ទីក្រុងភ្នំពេញ : អង្គការយូនីសេហ្វ ប្រចាំនៅ កម្ពុជា ។

អង្គការយូអ៊ិនអេដស៍ អង្គការយូនីសេហ្វ អង្គការ USAID (២០០៤) ។ " កុមារ ស្ថិតនៅចំណុចជិតគ្រោះថ្នាក់ ឆ្នាំ ២០០៤។ របាយការណ៍រួម ស្តីពីចំនួនប៉ាន់ស្មាន លើកុមារកំព្រាថ្មី និង ក្របខ័ណ្ឌការ ងារ សំរាប់អនុវត្តសកម្មភាព " ។ ញូវយ៉ក : អង្គការយូនីសេហ្វ។

ការស្រាវជ្រាវរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតសម្បទា ទៅលើកុមារអនាថាតាមចិញ្ចើមថ្នល់ ឆ្នាំ ២០០៤ ។

អង្គភាពឃ្លាំមើល ( ២០០៤ ) :ការឃ្លាំមើលស្ថានភាពមេរោគអេដស៍ ( HSS ) ឆ្នាំ ២០០៣ : លទ្ធផលទំនោរ និង ការប៉ាន់ស្មាន ។ ទីក្រុងភ្នំពេញ : មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងមេរោគអេដស៍- ជំងឺអេដស៍ ជម្ងឺសើរស្បែកនិងកាមរោគ ( NCHADS )។

Steinfatt,T.M ( 2003 ) ។ ការវាស់ចំនួនស្ត្រី និង កុមារ ដែលត្រូវគេជួញដូរនៅក្នុងប្រទេសកម្ពុជា :ការសិក្សាតាមមូលដ្ឋានសង្កេតមើលផ្ទាល់ ។ ទីក្រុងភ្នំពេញ : អង្គការ USAID

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ( ២០០១ ) " ការអង្កេតថ្នាក់ជាតិ ទៅលើអ្នកផ្តល់ការថែទាំចំលាស់សំរាប់កុមារនៅកម្ពុជា " ។ ទីក្រុងភ្នំពេញ : ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទា ជាមួយ ការគាំទ្របច្ចេកទេសពី អង្គការយូនីសេហ្វ ។

Tolfree, D. (១៩៩៥ )។ ដំបូល និង បូស ។ ការថែទាំកុមារបាក់បែកក្រុមគ្រួសារ នៅប្រទេសកំពុងអភិវឌ្ឍន៍ ។ ទីក្រុងឡុង : អង្គការចក្រភពអង់គ្លេសសង្គ្រោះកុមារ ។

ច្បាប់កម្ពុជា ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ( ១៩៨៩ ) មាត្រា ១០៣ ។

សេចក្តីព្រាងច្បាប់រដ្ឋប្បវេណី ឆ្នាំ ២០០៣ ។

សេចក្តីព្រាងច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសឆ្នាំ ២០០៦ ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ២០ ។

សន្និសីទអន្តរជាតិលើកទីពីរ ស្តីពីកុមារ និង ការថែទាំនៅក្នុងមណ្ឌល (ខែ ឧសភា ២០០៣ ) ។ សេចក្តីប្រកាស ទីក្រុងស្តុកខុល ស្តីពីកុមារ និង ការថែទាំនៅក្នុងមណ្ឌល ។

[១៣] ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ( ខែ តុលា ឆ្នាំ ២០០៣ ) ។ របាយការណ៍ស្តីពីសន្និសីទក្រោយសន្និសីទអន្តរជាតិ ទីក្រុងស្តុកខុល " កុមារ និង ការថែទាំ នៅតាមមណ្ឌលស្នាក់នៅរយៈពេលយូរ " ថ្ងៃទី ១៤-១៥ ខែ តុលា ឆ្នាំ ២០០៣ ។ ទីក្រុងភ្នំពេញ : ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

សន្និសីទអន្តរជាតិលើកទីពីរ ស្តីពីកុមារ និង ការថែទាំនៅក្នុងមណ្ឌល (ខែ ឧសភា ២០០៣ ) ។ សេចក្តីប្រកាស ទីក្រុងស្តុកខុល ស្តីពីកុមារ និង ការថែទាំនៅក្នុងមណ្ឌល ។

[១៣] ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ( ខែ តុលា ឆ្នាំ ២០០៣ ) ។ របាយការណ៍ស្តីពីសន្និសីទក្រោយសន្និសីទអន្តរជាតិ ទីក្រុងស្តុកខុល " កុមារ និង ការថែទាំ នៅតាមមណ្ឌលស្នាក់នៅរយៈពេលយូរ " ថ្ងៃទី ១៤-១៥ ខែ តុលា ឆ្នាំ ២០០៣ ។ ទីក្រុងភ្នំពេញ : ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

[១៤] អនុសញ្ញា ស្តីពីសិទ្ធិកុមារ (ឆ្នាំ ១៩៩២) : ពិធីសារជំរើស ស្តីពីការលក់ដូរកុមារ កុមារពេស្យាចារ និង រូបអាសអាភាសកុមារ ( ២០០០ ) ស្តីពីការពាក់ព័ន្ធរបស់កុមារនៅក្នុងជំលោះប្រដាប់អាវុធ ( ២០០០ ) អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ និង ស្ថាប័ន និង ការអនុវត្តន៍នានា ដែលស្រដៀងគ្នាទៅនឹងទាសភាព ( ផ្តល់សច្ចាប័ន នៅ ឆ្នាំ ១៩៥៧ ) អនុសញ្ញាស្តីពីពលកម្មដោយបង្ខិតបង្ខំ ( ផ្តល់សច្ចាប័ននៅឆ្នាំ ១៩៧០ ) អនុសញ្ញា ឆ្នាំ ២០០០ ប្រឆាំងនឹងឧក្រិដ្ឋកម្ម

អន្តរជាតិ ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និង ដាក់ទោស ការជួញដូរមនុស្ស ជាពិសេស ស្ត្រី និង កុមារ (ពិធីសារ I) និង ប្រឆាំងការរត់ពន្ធមនុស្ស បំលាស់ទីលំនៅតាមដីគោក សមុទ្រ និង តាមផ្លូវអាកាស (ពិធីសារII) (២០០១) អនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ចសង្គម និង វប្បធម៌ (១៩៨០) អនុសញ្ញាពាក់ព័ន្ធ និង អាយុអប្បរិមាសំរាប់ធ្វើការងារ (១៩៧៣) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់រូបភាពនៃការរើសអើងប្រឆាំងស្ត្រីភេទ (១៩៩២) ពិធីសារជំរើសបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់រូបភាពនៃការរើសអើងប្រឆាំងស្ត្រីភេទ (២០០១) ។

[១៥] សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិជនពិការ។

[១៦] សេចក្តីប្រកាសស្តីពីគោលការណ៍សង្គម និង ច្បាប់នានា ដែលទាក់ទងទៅនឹង កិច្ចការពារ និង សុខុមាលភាពរបស់កុមារ ហើយនិង មានខ្លឹមសារពិសេសពាក់ព័ន្ធទៅនឹង ការដាក់កុមារអោយគេចិញ្ចឹមជាកូនធម៌ និង ជាកូនចិញ្ចឹមក្នុងប្រទេស និង ក្រៅប្រទេស ។

[១៧] ច្បាប់អង្គការសហប្រជាជាតិ សំរាប់ការពារអនីតិជន ដែលត្រូវបានគេដកហូតសេរីភាព ។

[ឌ] ចំណែក UNAIDS អង្គការយូនីសេហ្វ និង USAID វិញ បានកំណត់និយមន័យ " កុមារកំព្រា " ដូចតទៅ ÷

- កុមារកំព្រាម្តាយ គឺជាកុមារដែលម្តាយបានស្លាប់ចោល ។ ចំណែកឯ ឪពុកវិញ អាចនៅមាន ជីវិតរស់នៅ ឬក៏មិនដឹងថានៅទីណាទេ (រួមបញ្ចូល កុមារកំព្រា ទាំងឪពុក ទាំងម្តាយ ) ។
- កុមារកំព្រាឪពុក គឺជាកុមារដែលឪពុកបានស្លាប់ចោល ។ ចំណែកឯ ម្តាយវិញ អាចនៅមាន ជីវិតរស់នៅ ឬក៏មិនដឹងថានៅទីណាទេ ( រួមបញ្ចូលកុមារកំព្រាទាំងឪពុកទាំងម្តាយ ) ។
- កុមារដែលកំព្រា ទាំងឪពុក ទាំងម្តាយ គឺជាកុមារដែលឪពុកម្តាយបានស្លាប់ចោល ។

[១៩] សូមមើលកំណត់សំគាល់លេខ ១៥

[២០] អនុស្សរណៈយោគយល់គ្នា រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារ និង ស្ត្រី និង ជួយជនរងគ្រោះដោយសារការជួញដូរ ( ឧសភា ២០០៣ ) ។